**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការលុបចោល និងមោឃភាព នៃកិច្ចសន្យា ក្រោមបទប្បញ្ញត្តិ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


| ស្រាវជ្រាវដោយ | | សាស្ត្រាចារ្យណែនាំ |
|---|---|---|
| និស្សិតឈ្មោះ | **ក. ឡូញ សុខខា** | **លោកស្រី ម៉ូយ ធីតា** |
| | **ក. ឆុន គឹមសាន** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលសិក្សា | ២០១៤ |
| ជំនាន់ទី ១៨ | | ឆ្នាំសរសេរសារណា | ២០១៨ |

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំ **ឡូញ សុខខា** និង នាងខ្ញុំ **ធុន គីមសាន** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្ដែងនូវការដឹងគុណ និងគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ លោកឪពុក **នុត តិ** អ្នកម្ដាយ **ជឹង ស៊ីណាត** និងលោកឪពុក **ទូច គីមហេង** អ្នកម្ដាយ **ម៉ាក សារុំ** ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតរបស់កូន ដែលលោកអ្នកមានគុណបានផ្ដល់កំណើត ក្ដីស្រឡាញ់ ភាពកក់ក្ដៅ និងខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីនៅក្នុងផ្ទៃរហូតដល់កូនធំពេញវ័យ។ លើសពីនេះទៅទៀត លោកអ្នកទាំងពីរបានទូន្មានប្រៀនប្រដៅកូន ហើយខិតខំធ្វើការទាំងថ្ងៃទាំងយប់គ្មានពេលណាសម្រាកបានស្រួលឡើយ ក្នុងគោលបំណងស្វែងរកប្រាក់មកចិញ្ចឹម និងផ្ដល់ការឧបត្ថម្ភដល់កូនក្នុងការរៀនសូត្ររហូតបានបញ្ចប់ការសិក្សាថ្នាក់សាកលវិទ្យាល័យយ៉ាងជោគជ័យ។ បន្ថែមលើនេះ នាងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអ៊ំប្រុស អ៊ំស្រី លោកពូ អ្នកមីង បងប្រុស បងស្រី ដែលបានលើកទឹកចិត្ត និងទំនុកបម្រុងទាំងផ្នែកស្មារតី រួមជាមួយសម្ភារដល់រូបនាងខ្ញុំក្នុងការសិក្សា។

ជាងនេះទៅទៀត នាងខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ៖

- ថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ដែលបានយកចិត្តទុកដាក់បង្ហាត់បង្រៀន និងផ្ដល់ចំណេះដឹងដល់នាងខ្ញុំទាំងពីរនាក់ ក៏ដូចជានិស្សិតដទៃទៀតកន្លងមក ដោយមិនគិតពីការនឿយហត់ ព្រមទាំងរិះរកនូវវិធីសាស្ត្របង្រៀនដ៏ប៉ិនប្រសព្វ ដែលអាចឱ្យសិស្សងាយយល់ ងាយចាំ និងទទួលបាននូវពុទ្ធិផ្នែកច្បាប់នេះ។
- ជាពិសេសគឺ អ្នកគ្រូសាស្ត្រាចារ្យ **ប៊ូយ ធីតា** ដែលមិនត្រឹមតែបានបង្ហាត់បង្រៀនប៉ុណ្ណោះទេ ថែមទាំងបានជួយជ្រោមជ្រែង ណែនាំ បង្ហាត់បង្ហាញ ក្នុងការសរសេរសារណានេះ ទោះបីជាអ្នកគ្រូមានការមមាញឹកយ៉ាងណាក៏ដោយ។

ជាចុងក្រោយ នាងខ្ញុំទាំងពីរនាក់ សូមគោរពដឹងគុណ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់នៅក្នុងលោក តាមជួយថែរក្សាការពារលោកឪពុក អ្នកម្ដាយ ព្រមទាំងអ្នកដែលបានរៀបរាប់ដូចខាងលើ ទទួលបានសេចក្ដីសុខសប្បាយ មានសុខភាពល្អ ជោគជ័យក្នុងការបំពេញភារកិច្ច និងជួបប្រទះតែពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ រយៈពេលបួនឆ្នាំរួចមក នាងខ្ញុំទាំងពីរបានទទួលនូវចំណេះដឹងយ៉ាងច្រើនទាំងផ្នែកទ្រឹស្តី និងការលើកឡើងនូវឧទាហរណ៍ដែលកើតមានឡើងក្នុងសង្គមជាក់ស្តែងពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ ដែលធ្វើឱ្យការសិក្សាផ្នែកច្បាប់នេះកាន់តែងាយយល់។ ក្នុងចំណោមមុខវិជ្ជាដែលបានសិក្សាកន្លងមក នាងខ្ញុំទាំងពីរនាក់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិរដ្ឋប្បវេណី។ នេះហើយដែលជាកត្តាជំរុញចិត្តឱ្យនាងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទ «**ការលុបចោល និងមោឃភាពកិច្ចសន្យាក្រោមបទប្បញ្ញត្តិក្រមរដ្ឋប្បវេណីឆ្នាំ២០០៧**» មកចងក្រងជាសារណាសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

មោឃភាព និងការលុបចោលកិច្ចសន្យា គឺជាមូលហេតុដែលធ្វើឱ្យកិច្ចសន្យាបាត់បង់អានុភាព។ មេរៀនមោឃភាព និងការលុបចោលកិច្ចសន្យានេះ គឺជាមេរៀនដែលគួរឱ្យចាប់អារម្មណ៍ និងមានអត្ថប្រយោជន៍ណាស់ ដើម្បីដឹងថាតើកិច្ចសន្យាប្រភេទណាដែលអាចត្រូវបានលុបចោល និងកិច្ចសន្យាប្រភេទណានឹងត្រូវមោឃភាព ហើយថាតើវាមានអានុភាពបែបណានៅពេលកិច្ចសន្យាត្រូវបានប្រកាសលុបចោល ឬមោឃភាព។ ម្យ៉ាងវិញទៀត ប្រធានបទនេះ ក៏ជាប្រធានបទមួយដែលមិនទាន់ត្រូវបានធ្វើការសិក្សាស្រាវជ្រាវឱ្យបានទូលំទូលាយនៅឡើយ។ នៅក្នុងការចងក្រងសារណានេះ នាងខ្ញុំទាំងពីរនាក់បានពឹងផ្អែកទៅលើអត្ថបទច្បាប់មួយចំនួនដូចជាៈ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ច្បាប់ស្តីពីការអនុវត្តក្រម សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី កម្រងសៀវភៅមេរៀនក្រមរដ្ឋប្បវេណី និងអត្ថបទគតិយុត្តផ្សេងទៀតជាច្រើនផងដែរ ដើម្បីធ្វើឱ្យកំហុសឆ្គងមានតិចបំផុតតាមដែលអាចធ្វើបាន។

នាងខ្ញុំទាំងពីរនាក់សង្ឃឹមថា សារណានេះនឹងចូលរួមចំណែកជួយសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវដទៃទៀត ទាក់ទងនឹងសុពលភាពនៃកិច្ចសន្យា។ យ៉ាងណាមិញ ដោយសារចំណេះដឹងជាមូលដ្ឋាន ការសិក្សាស្រាវជ្រាវ ក៏ដូចជា ឯកសារសិក្សាស្រាវជ្រាវបន្ថែម និងការរៀបចំចងក្រងជាសារណារបស់នាងខ្ញុំទាំងពីរនាក់នៅមានកម្រិត ពួកយើងជឿជាក់ថា ចំណុចខ្វះខាតពិតជាមានលេចឡើងយ៉ាងពិតប្រាកដ។ ពួកយើងរីករាយទទួលយកនូវរាល់ការរិះគន់ដើម្បីស្ថាបនាពីសំណាក់សាស្ត្រាចារ្យ រៀមច្បង និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ដើម្បីឱ្យស្នាដៃនេះកាន់តែល្អប្រសើរឡើង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១**

**ការលុបចោលកិច្ចសន្យា**

**១.១ និយមន័យ «ការលុបចោល»** ........................................................ ៣

**១.២ មូលហេតុនៃការលុបចោលកិច្ចសន្យា** ........................................................ ៤

**១.២.១ វិការៈនៃការបង្ហាញឆន្ទៈ** ........................................................ ៤

១.២.១.១ ការភាន់ច្រឡំ ........................................................ ៤

១.២.១.២ ការឆបោក ........................................................ ៩

១.២.១.៣ ព័ត៌មានមិនពិត ........................................................ ១២

១.២.១.៤ ការរំលោភបំពានលើស្ថានភាព ........................................................ ១៣

១.២.១.៥ ការគម្រាមកំហែង ........................................................ ១៥

១.២.១.៦ អំពីការកេងចំណេញហួសហេតុ ........................................................ ១៧

**១.២.២ ការខ្វះសមត្ថភាពរបស់គូភាគី** ........................................................ ១៨

១.២.២.១ ការខ្វះសមត្ថភាពខាងឆន្ទៈ ........................................................ ១៨

១.២.២.២ ការខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព ........................................................ ១៨

ក. អនីតិជន ........................................................ ១៩

ខ. ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ........................................................ ២៣

គ. ជនស្ថិតនៅក្រោមហិតូបត្ថម្ភ ........................................................ ២៥

**១.៣ អ្នកដែលមានសិទ្ធិលុបចោល និងផ្តល់សច្ចានុមតិ** ........................................................ ២៧

**១.៣.១ អ្នកមានសិទ្ធិលុបចោល** ........................................................ ២៧

១.៣.១.១ អ្នកមានសិទ្ធិលុបចោលចំពោះកិច្ចសន្យាដែលមានវិការៈ ........................................................ ២៧

១.៣.១.២ អ្នកមានសិទ្ធិលុបចោលចំពោះកិច្ចសន្យាធ្វើឡើង
ដោយជនខ្វះសមត្ថភាព ........................................................ ២៨

**១.៣.២ អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ** ........................................................ ៣០

**១.៤ វិធីនៃការលុបចោលកិច្ចសន្យា និងការផ្ដល់សច្ចានុមតិ** ........................................ ៣១
១.៤.១ វិធីនៃការលុបចោលកិច្ចសន្យា ........................................ ៣០
១.៤.២ វិធីនៃការផ្ដល់សច្ចានុមតិ........................................ ៣១
**១.៥ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល**........................................ ៣៣
**១.៦ អានុភាពនៃការលុបចោល** ........................................ ៣៥

## ជំពូកទី២
## មោឃភាពកិច្ចសន្យា

**២.១ និយមន័យ «មោឃភាព»** ........................................ ៣៧
**២.២ មូលហេតុនៃមោឃភាពកិច្ចសន្យា**........................................ ៣៧
២.២.១ ការបង្ហាញឆន្ទៈមិនពិត........................................ ៣៨
២.២.២ ភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ........................................ ៤០
២.២.៣ ភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ
ក្នុងអត្ថន័យនៃកិច្ចសន្យា ........................................ ៤១
២.២.៤ កិច្ចសន្យាផ្ទុយនឹងទម្រង់ដែលច្បាប់បានកំណត់........................................ ៤២
**២.៣ អ្នកដែលមានសិទ្ធិលើកឡើងពីមោឃភាពកិច្ចសន្យា**........................................ ៤៣
**២.៤ វិធីនៃការលើកឡើងពីមោឃភាពកិច្ចសន្យា**........................................ ៤៤
**២.៥ អាជ្ញាយុកាលនៃការលើកឡើងពីមោឃភាពកិច្ចសន្យា** ........................................ ៤៥
**២.៦ អានុភាពនៃមោឃភាពកិច្ចសន្យា**........................................ ៤៥
២.៦.១ មោឃភាពដាច់ខាត ........................................ ៤៥
២.៦.២ មោឃភាពមិនដាច់ខាត........................................ ៤៨
**សេចក្ដីសន្និដ្ឋាន**........................................ ៥០
**អនុសាសន៍** ........................................ ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ យើងបានបង្កើតកិច្ចសន្យាជាច្រើន ដែលពេលខ្លះយើងពុំចាប់អារម្មណ៍ឡើយ។ ជាពិសេសការធ្វើជំនួញដូរ គឺជាសកម្មភាពមួយដែលកើតមានឡើងជាប្រចាំនៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារសេរី។ ដើម្បីឱ្យការជួញដូរមានភាពរលូន ភាគីនៃការជួញដូរ គួរតែមានសេរីភាព និងសមភាពនៅក្នុងការជួញដូរ។ ហេតុដូច្នេះហើយ ទើបក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់គោលការណ៍ស្វ័យភាពបុគ្គលឯកជន ផ្ដល់សិទ្ធិឱ្យភាគីនៃកិច្ចសន្យាអាចកំណត់ពីខ្លឹមសារនៃកិច្ចសន្យាដោយសេរីតាមឆន្ទៈរបស់ខ្លួន ដោយមិនត្រូវចងដោយឆន្ទៈបុគ្គលដទៃឡើយបើខ្លួនមិនយល់ព្រម។ បន្ថែមពីនេះទៀតផងដែរ នៅក្នុងទំនាក់ទំនងកិច្ចសន្យា តែងមានបុគ្គលដែលមានករណីយកិច្ច ឬហៅថាកូនបំណុល និងបុគ្គលដែលជាអ្នកទទួលផលប្រយោជន៍ ឬហៅថាម្ចាស់បំណុល ដូច្នេះហើយ ភាគីនៃកិច្ចសន្យាត្រូវប្រើសិទ្ធិ ឬអនុវត្តករណីយកិច្ចដោយគោរពទៅតាមគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។ យ៉ាងណាមិញ ប្រជាពលរដ្ឋកម្ពុជាយើងមួយចំនួនពុំបានស្វែងយល់ពីច្បាប់ជាមុន មុននឹងបង្កើតកិច្ចសន្យាផ្សេងៗនោះទេ ខណៈដែលមានបញ្ហាកើតឡើង ទើបស្វែងរកអ្នកច្បាប់ឱ្យជួយដោះស្រាយ លើកលែងតែអ្នកវិនិយោគ អ្នកជំនួញ ឬអាជីវករ អ្នករកស៊ីធំៗ ដែលពួកគាត់តែងមានទីប្រឹក្សាច្បាប់ម្នាក់ ឬច្រើន ដើម្បីប្រឹក្សាយោបល់ផ្នែកច្បាប់ផ្សេងៗ ជៀសវាងមានបញ្ហាប៉ះពាល់ដល់កិច្ចការជំនួញរបស់ខ្លួន។ កិច្ចសន្យាដែលកើតឡើងជាញឹកញាប់នៅក្នុងជីវិតប្រចាំថ្ងៃ ក៏ដូចជានៅក្នុងសង្គមកម្ពុជាយើងមានដូចជា៖ កិច្ចសន្យាទិញលក់ កិច្ចសន្យាខ្ចីប្រើ កិច្ចសន្យាម៉ៅការជាដើម។ ដូចដែលយើងដឹងហើយថា ប្រទេសកម្ពុជាយើង គឺជាប្រទេសនីតិរដ្ឋ ដូចនេះការធ្វើអ្វីផ្សេងៗត្រូវតែអនុលោមទៅតាមច្បាប់ ហើយច្បាប់អាចការពារ និងផ្ដល់អត្ថប្រយោជន៍ដល់យើងបានលុះត្រាតែយើងគោរពទៅតាមបញ្ញត្តិច្បាប់។ ហេតុនេះហើយ ទោះបីជាកិច្ចសន្យាត្រូវបានបង្កើតឡើងក៏ដោយ ប្រសិនបើកិច្ចសន្យានោះ ពុំបានបំពេញនូវលក្ខខណ្ឌដែលកំណត់ដោយច្បាប់ ឬផ្ដល់ផលប៉ះពាល់ដល់ភាគីនៃកិច្ចសន្យា និងសង្គម នោះកិច្ចសន្យានឹងប្រឈមនឹងការប្រកាសលុបចោលទៅវិញ ឬត្រូវបានចាត់ទុកជាមោឃៈ។ ជាការគួរកត់សម្គាល់មួយគឺ ជាគោលការណ៍ កិច្ចសន្យាមានអានុភាពត្រឹមដំណាក់កាលសំណើ និងស្វីការត្រូវគ្នា តែក៏មានកិច្ចសន្យាខ្លះទាមទារឱ្យបំពេញលក្ខខណ្ឌបន្ថែមទៀតក្រៅពីមានភាពត្រូវគ្នារវាងសំណើ និងស្វីការ។ ជាក់ស្ដែង ចំពោះកិច្ចសន្យាដែលមានការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនឹងមានអានុភាពបាន លុះត្រាតែបានធ្វើលិខិតយថាភូតបន្ថែមពីលើភាពត្រូវគ្នារវាងសំណើ និងស្វីការ។ ដូច្នេះហើយ តើក្នុងដំណាក់កាលណាដែលអាចឱ្យគេប្រកាសលុបចោលកិច្ចសន្យា ឬលើកឡើងពីមោឃភាពកិច្ចសន្យាបាន? តើនរណាខ្លះមានសិទ្ធិ

ប្រកាសលុបចោលកិច្ចសន្យា ឬលើកឡើងពីមោឃភាពកិច្ចសន្យា? ហើយថាតើការប្រកាសលុបចោលកិច្ចសន្យា ឬលើកឡើងពីមោឃភាពកិច្ចសន្យានាំអោយមានអានុភាពបែបណា?

ភ្ជាប់ទៅនឹងការរៀបរាប់ខាងលើ បើយើងក្រឡេកមើលបទប្បញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ យើងអាចធ្វើការបែងចែកជាពីរគឺ ចំពោះកិច្ចសន្យាដែលមានផលប៉ះពាល់ត្រឹមជាលក្ខណៈបុគ្គល ពោលគឺភាគីនៃកិច្ចសន្យា នោះកិច្ចសន្យាអាចត្រូវបានលុបចោល លើសពីនេះ ប្រសិនបើកិច្ចសន្យាមានផលប៉ះពាល់ជាលក្ខណៈសាធារណៈដូចជា៖ ទំនៀមទម្លាប់សណ្តាប់ធ្នាប់ល្អរបស់សង្គម ឬផ្ទុយច្បាប់ជាដើម កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ។

ដូចនេះ ការស្វែងយល់ពីការលុបចោល និងមោឃភាពកិច្ចសន្យា ពិតជាមានសារៈសំខាន់ណាស់។ នៅក្នុងសៀវភៅនេះ យើងនឹងធ្វើការសិក្សាអំពីមូលហេតុអ្នកដែលមានសិទ្ធិលុបចោល ក៏ដូចជាអ្នកមានសិទ្ធិលើកឡើងពីមោឃភាព អាជ្ញាយុកាល អានុភាព ហើយយើងនឹងធ្វើការសិក្សាវែកញែកជាពីរគឺ *ការលុបចោលកិច្ចសន្យា (ជំពូកទី១) និងមោឃភាពកិច្ចសន្យា (ជំពូកទី២)*។

# ជំពូកទី១
# ការលុបចោលកិច្ចសន្យា

កិច្ចសន្យាកើតឡើងនៅពេលដែលសំណើ និងស្វីការត្រូវគ្នា។[1] **សំណើ** គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈ ភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។[2] ចំណែកឯ **ស្វីការ** គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។[3] នៅក្នុងការបង្កើតកិច្ចសន្យា យើងគប្បីគិតទៅដល់លក្ខខណ្ឌពីរគឺ លក្ខខណ្ឌអានុភាព និងលក្ខខណ្ឌសុពលភាព។ ចំពោះលក្ខខណ្ឌអានុភាពអាចបែងចែកជាពីរករណីគឺ ការព្រមព្រៀង និងករណីលើកលែង។ ជាគោលការណ៍ កិច្ចសន្យាមានអានុភាពនៅពេលដែលភាគីទាំងពីរមានការព្រមព្រៀងគ្នាទៅវិញទៅមក។ ជាអញ្ញត្រកម្ម កិច្ចសន្យាមួយចំនួន ទោះបីជាសំណើ និងស្វីការត្រូវគ្នាក៏ដោយ ក៏កិច្ចសន្យានោះពុំទាន់មានអានុភាពដែរ ពោល គឺកិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។[4] ចំពោះលក្ខខណ្ឌសុពលភាព យើងនឹងសិក្សាលម្អិតនៅក្នុងសៀវភៅនេះ។ កិច្ចសន្យាមានសុពលភាព លុះត្រាតែកិច្ចសន្យានោះគ្មានមូលហេតុនៃការលុបចោល និងគ្មានមូលហេតុនៃមោឃភាព។ ជំពូកទី១នេះ នឹងធ្វើការសិក្សាលម្អិតអំពីការលុបចោលកិច្ចសន្យា ដោយផ្តោតលើផ្នែកសំខាន់ៗចំនួន៦ គឺ (១.១) និយមន័យ (១.២) មូលហេតុ (១.៣) អ្នកមានសិទ្ធិលុបចោល (១.៤) វិធីនៃការលុបចោល និងការផ្តល់សច្ចានុមតិ (១.៥) អាជ្ញាយុកាល និង (១.៦) អានុភាព។

## ១.១ និយមន័យ «ការលុបចោល»

**ការលុបចោល** គឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយផ្សេងទៀតដែលនាំឱ្យកិច្ចសន្យាក្លាយជាមោឃៈ។ **ការលុបចោលកិច្ចសន្យា** គឺជាសកម្មភាពឯកតោភាគីរបស់អ្នកដែលមានសិទ្ធិលុបចោល ដោយផ្អែកលើមូលហេតុណាមួយនៃការលុបចោល។ កិច្ចសន្យាអាចត្រូវបានលុបចោលដោយមូលហេតុវិការៈក្នុងការបង្ហាញឆន្ទៈ និងមូលហេតុខ្វះសមត្ថភាពរបស់ភាគី។

[1] មាត្រា៣៣៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, (ពីពេលនេះទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)

[2] មាត្រា៣៣៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[3] មាត្រា៣៣៧ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[4] មាត្រា៣៣៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ១.២ មូលហេតុនៃការលុបចោលកិច្ចសន្យា

### ១.២.១ វិការៈនៃការបង្ហាញឆន្ទៈ

ដើម្បីជាមូលដ្ឋានក្នុងការស្វែងយល់នូវចំណុចនីមួយៗ នៃការបង្ហាញឆន្ទៈដោយមានវិការៈ យើងគប្បីយល់ន័យពាក្យ «**វិការៈ**» និង «**ការបង្ហាញឆន្ទៈ**» ជាមុនសិន។ យោងតាមសន្ទានុក្រមនៃក្រមរដ្ឋប្បវេណី ចំណុច១៣៥ ពាក្យថា «**វិការៈ**» មានន័យថា ការប្រែប្រួលចាកពីភាពប្រក្រតី។ ចំណែកឯពាក្យ «**ការបង្ហាញឆន្ទៈ**» មានចង្អុលបង្ហាញនៅក្នុងមាត្រា៣១០ កថាខណ្ឌ១ ដែលសំដៅលើការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត។ ដូចនេះ **វិការៈនៃការបង្ហាញឆន្ទៈ** មានន័យថា ការប្រែប្រួលចាកពីភាពប្រក្រតីនៃការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត។ ជាទូទៅ ការបង្ហាញឆន្ទៈ មានលក្ខណៈពិតប្រាកដដោយសេរី និងស្ម័គ្រចិត្តពោល គឺពុំត្រូវមានហេតុណាមួយដែលធ្វើឱ្យឆន្ទៈបង្ហាញដែលនោះ មិនត្រឹមត្រូវទៅតាមឆន្ទៈពិតប្រាកដរបស់ភាគី។ ស្ថានភាពដែលចាត់ទុកថាជាវិការៈនៃការបង្ហាញឆន្ទៈ មានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា៣៤៦ ដល់មាត្រា៣៥១ ដែលរួមមាន៖ ការបង្ហាញឆន្ទៈដោយមានការភាន់ច្រឡំ ការបង្ហាញឆន្ទៈដោយមានការឆបោក ការបង្ហាញឆន្ទៈព្រោះទទួលបានព័ត៌មានមិនពិត ការបង្ហាញឆន្ទៈដោយស្ថិតក្នុងការរំលោភលើស្ថានភាព ការបង្ហាញឆន្ទៈដោយមានការគម្រាមកំហែង និងការបង្ហាញឆន្ទៈដែលភាគីម្ខាងទៀតបានកេងចំណេញយ៉ាងហួសហេតុ។ យើងនឹងធ្វើការសិក្សាពីចំណុចនីមួយៗដូចខាងក្រោម៖

#### ១.២.១.១ ការភាន់ច្រឡំ

យើងដឹងហើយថា ការបង្ហាញឆន្ទៈដោយពិតប្រាកដ ដោយសេរី និងស្មោះត្រង់ គឺជាធាតុផ្សំដ៏សំខាន់ក្នុងការបង្កើតកិច្ចសន្យា ដូចនេះ ប្រសិនបើភាគីណាម្ខាងនៃកិច្ចសន្យាបង្ហាញឆន្ទៈដោយភាន់ច្រឡំ កិច្ចសន្យានោះពុំគួរមានសុពលភាពឡើយ ព្រោះថាជាទូទៅ គោលបំណងរបស់ភាគីក្នុងការបង្កើតកិច្ចសន្យា គឺដើម្បីទទួលបាននូវអ្វីដែលខ្លួនបានរំពឹងទុក ហើយកិច្ចសន្យាដែលកើតឡើងពីការបង្ហាញឆន្ទៈដោយភាន់ច្រឡំ លទ្ធផលប្រាកដជាខុសពីការរំពឹងទុករបស់ភាគីដែលធ្វើឱ្យអ្នកបង្ហាញឆន្ទៈនឹងមានការខកបំណង។ ហេតុនេះហើយ បានជាក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យអ្នកដែលបង្ហាញឆន្ទៈដោយភាន់ច្រឡំអាចធ្វើការលុបចោលកិច្ចសន្យានោះបាន។ ទោះបីជាយ៉ាងណាក៏ដោយក៏បញ្ញត្តិមិនធូរលុងពេកដែរ ព្រោះថា ការភាន់ច្រឡំ គឺកើតចេញពីភាគីតែម្ខាងប៉ុណ្ណោះ ដូចនេះ ប្រសិនបើអនុញ្ញាតឱ្យអ្នកដែលបង្ហាញឆន្ទៈដោយការភាន់ច្រឡំ អាចបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាវិញដោយងាយៗនោះ វាពិតជាអយុត្តិធម៌សម្រាប់ភាគីម្ខាងទៀតណាស់ ព្រោះថាភាគីនីមួយៗសុទ្ធតែមានក្តីរំពឹង និងគិតថាខ្លួនបានទទួលប្រយោជន៍ពីកិច្ចសន្យាដែលខ្លួនបានបង្កើត។ ដើម្បីឱ្យ

ភាគីទាំងសងខាងទទួលបាននូវយុត្តិធម៌ និងសមភាព ច្បាប់តម្រូវឱ្យបំពេញនូវលក្ខខណ្ឌមួយចំនួន ទើបកិច្ចសន្យាដែលកើតឡើងដោយការភាន់ច្រឡំនៃការបង្ហាញឆន្ទៈអាចលុបចោលបាន។

បទប្បញ្ញត្តិទាក់ទងនឹង **«ការភាន់ច្រឡំ»** មានចែងនៅក្នុងមាត្រា៣៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ **ការភាន់ច្រឡំ** មានន័យថា គឺជាការបង្ហាញឆន្ទៈទៅលើកិច្ចសន្យាដោយការយល់ច្រឡំអំពីខ្លឹមសារនៃកិច្ចសន្យា។[5] ស្ថានភាពនៃការភាន់ច្រឡំមានលក្ខណៈខុសៗគ្នា ដែលអាចធ្វើការបែងចែកជា ៣ស្ថានភាព ដូចខាងក្រោម៖

***ស្ថានភាពទី១៖***

លក្ខខណ្ឌដែលត្រូវបំពេញមាន៣ គឺ៖[6]

(១) ភាគីម្ខាងមានការភាន់ច្រឡំ

(២) ការភាន់ច្រឡំលើចំណុចសំខាន់នៃកិច្ចសន្យា និង

(៣) ភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនោះ។

លក្ខខណ្ឌទាំង៣នេះ បើមើលមួយភ្លែតហាក់ដូចជាមិនពិបាកយល់ និងងាយចងចាំ ប៉ុន្តែក្នុងការបកស្រាយទាមទារឱ្យយើងយល់ឱ្យច្បាស់ ថាតើអ្វីទៅដែលចាត់ទុកថាជាចំណុចសំខាន់នៃកិច្ចសន្យា ហើយធ្វើយ៉ាងណាទើបដឹងថាភាគីម្ខាងទៀតអាចដឹងអំពីការភាន់ច្រឡំ។ ចំណុចសំខាន់នៃកិច្ចសន្យានៅត្រង់នេះ សំដៅលើចំណុចសំខាន់តាមសត្យានុម័ត បានន័យថា មនុស្សទូទៅក្នុងសង្គមយល់ឃើញថា **សំខាន់**។ ម្យ៉ាងវិញទៀត យើងក៏អាចធ្វើការពិចារណាថា ការភាន់ច្រឡំអំពីចំណុចពិសេសនៃកិច្ចសន្យា គឺជាការភាន់ច្រឡំលើ***កម្មវត្ថុ តម្លៃ និងទំហំ***។

ខាងក្រោមនេះ យើងនឹងលើកយកឧទាហរណ៍ដែលកើតមានក្នុងជីវភាពប្រចាំថ្ងៃមកបង្ហាញ ថាតើអាចលុបចោលបានឬទេ៖

***ឧទាហរណ៍ទី១៖*** នារី «ក» បានទៅផ្សារជាមួយកូនរបស់គាត់ ពេលដើរដល់តូបលក់ផ្លែឈើមួយ កូនរបស់នារី «ក» បានប្រាប់ថា «ម៉ាក់ ខ្ញុំចង់ញ៉ាំផ្លែស្រង៉ែន» ឮដូចនេះ នារី «ក» បានប្រាប់អ្នកលក់ «ខ» ថា «បង សូមខ្ចប់ផ្លែឈើនេះឱ្យខ្ញុំ២គីឡូ» ប៉ុន្តែតាមពិតផ្លែនោះគឺជាផ្លែមៀន មិនមែនស្រង៉ែនទេ។ តើនារី «ក» អាចលុបចោលកិច្ចសន្យាបានទេ?

ដើម្បីអាចឆ្លើយបានថាតើអាចលុបចោលបានឬទេ យើងត្រូវត្រួតពិនិត្យមើលថាលក្ខខណ្ឌទាំង៣ បានបំពេញឬអត់៖

[5] សៀវភៅក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ របស់ក្រសួងយុត្តិធម៌, ទំព័រ២២

[6] មាត្រា៣៤៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្នុងឧទាហរណ៍ខាងលើយើងឃើញថា៖

- នារី «ក» មានការភាន់ច្រឡំ (លក្ខខណ្ឌទី១)
- ការភាន់ច្រឡំថា មៀន គឺជា ស្រងែន ដែលជាចំណុចសំខាន់នៃកិច្ចសន្យា ព្រោះថាកូនរបស់ខ្លួនចង់ញ៉ាំស្រងែន មិនមែនមៀនទេ (លក្ខខណ្ឌទី២)
- អ្នកលក់ «ខ» អាច ឬបានដឹងថា នារី «ក» ចង់ទិញស្រងែន ព្រោះពេលកូនរបស់នារី «ក» និយាយនោះគឺនៅមុខតូបរបស់ «ខ» ដែល «ខ» អាចឮ (លក្ខខណ្ឌទី៣)។

***ដូចនេះ នារី «ក» អាចលុបចោលកិច្ចសន្យាបាន។***

***ឧទាហរណ៍ទី២៖*** នារី «ក» បានទៅផ្សារទំនើប ពេលដើរដល់កន្លែងដាក់តាំងលក់ផ្លែឈើ គាត់បានគិតថាចង់ទិញស្រងែនផ្ញើកូន ហើយបានយកមួយកញ្ចប់ទៅកន្លែងគិតលុយ ដោយមិនបានដឹងថាផ្លែឈើដែលច្រកស្រាប់នោះគឺជាផ្លែមៀន មិនមែនស្រងែនទេ។ តើនារី «ក» អាចលុបកិច្ចសន្យាបានទេ?

ក្នុងឧទាហរណ៍ទី២នេះ យើងឃើញថា៖

- នារី «ក» បានភាន់ច្រឡំ (លក្ខខណ្ឌទី១)
- ការភាន់ច្រឡំថា មៀន ជា ស្រងែន ដែលជាចំណុចសំខាន់នៃកិច្ចសន្យា (លក្ខខណ្ឌទី២)
- ភាគីម្ខាងទៀត ពុំអាចស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំរបស់នារី «ក» នោះទេ ព្រោះយើងដឹងហើយថា នៅផ្សារទំនើប អ្នកទិញជាអ្នកជ្រើសរើសទំនិញដោយខ្លួនឯង ទើបយកទៅគិតលុយ ដែលភាគីខាងអ្នកលក់ ឬអ្នកគិតលុយមិនដឹងថាយើងចង់ទិញអ្វីខ្លះនោះទេ (លក្ខខណ្ឌទី៣ មិនត្រូវបានបំពេញ)។

***ដូចនេះ នារី «ក» មិនអាចលុបចោលកិច្ចសន្យាបាននោះទេ។***

***<u>ស្ថានភាពទី២៖</u>***

លក្ខខណ្ឌដែលត្រូវបំពេញមាន៣ គឺ៖[7]

(១) ភាគីម្ខាងនៃកិច្ចសន្យាមានការយល់ច្រឡំ

(២) ការភាន់ច្រឡំលើចំណុចដែលខ្លួនយល់ឃើញថាសំខាន់នៃកិច្ចសន្យា ឬសំខាន់ក្នុងការបង្កើតកិច្ចសន្យា

[7] មាត្រា៣៤៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

(៣) ភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង

(៤) ភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ។

ការភាន់ច្រឡំនៅក្នុងស្ថានភាពទី២នេះ ចំណុចសំខាន់ដែលលើកឡើងនៅក្នុងលក្ខខណ្ឌទី១ គឺជាចំណុចសំខាន់តាមអត្តនោម័ត ពោលគឺអ្នកបង្ហាញឆន្ទៈយល់ឃើញថាសំខាន់សម្រាប់ខ្លួនក្នុងការបង្កើតកិច្ចសន្យា ទោះបីមិនមែនជាចំណុចដែលសាធារណជនទូទៅយល់ឃើញថាសំខាន់ក៏ដោយ។

***ឧទាហរណ៍ទី៣៖*** (អំពីការភាន់ច្រឡំលើចំណុចដែលខ្លួនយល់ឃើញថាសំខាន់)

លោក «ក» ជាអាជីវករលក់គ្រឿងសំណង់។ ជាធម្មតា គាត់បញ្ជាទិញទំនិញពីអ្នកបោះដុំដែលជាម៉ូយរបស់គាត់ក្នុងមួយសប្តាហ៍ម្តង ដោយតម្រូវឱ្យយកទំនិញមកដល់តូបរបស់គាត់នៅថ្ងៃចន្ទ ព្រោះគាត់គិតថាថ្ងៃចន្ទជាថ្ងៃដើមទ្រព្យ និងជាថ្ងៃល្អសម្រាប់គាត់។ ថ្ងៃមួយ លោក «ក» បានខលទៅម៉ូយរបស់គាត់ដើម្បីបញ្ជាទិញទំនិញ និងបានច្រឡំប្រាប់ថាយកទំនិញមកថ្ងៃពុធ។ លោក «ក» ចង់ធ្វើការលុបចោលសន្យា។

ក្នុងឧទាហរណ៍ទី៣នេះ យើងឃើញថា៖

- លោក «ក» បានភាន់ច្រឡំ (លក្ខខណ្ឌទី១)
- ការភាន់ច្រឡំលើថ្ងៃដែលត្រូវនាំយកទំនិញមកដល់ ជាចំណុចដែលគាត់យល់ថាសំខាន់នៃកិច្ចសន្យា (លក្ខខណ្ឌទី២)
- ភាគីម្ខាងទៀតដែលជាម៉ូយរបស់គាត់ ស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ ដោយសារធ្លាប់រកស៊ីជាមួយគ្នាច្រើនឆ្នាំហើយ (លក្ខខណ្ឌទី៣)
- ចំពោះលក្ខខណ្ឌទី៤ យើងមិនអាចសន្មតថាតើ ភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំរបស់លោក «ក» ឬទេ គឺអាស្រ័យលើភាគីអាចរកភស្តុតាងមកបញ្ជាក់។

***ដូចនេះ មាន២ករណីគឺ៖ (១) អាចលុបចោលបាន បើលោក «ក» អាចបញ្ជាក់បានថាភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំ និង (២) មិនអាចលុបចោលបានបើភាគីម្ខាងទៀតអាចអះអាងបានថា គាត់មិនអាចដឹងអំពីការភាន់ច្រឡំ។***

***ឧទាហរណ៍ទី៤៖*** (អំពីការភាន់ច្រឡំលើចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា)

កញ្ញា «ខ» បានទៅហាងរបស់ «គ» ដើម្បីទិញសម្លៀកបំពាក់ទុកជូនគូដណ្តឹង «ឃ» សម្រាប់ថ្ងៃខួបកំណើត។ «ខ» បានប្រាប់ «គ» ពេលកំពុងរើសមើលខោដែលព្យួរថា «គូដណ្តឹងខ្ញុំចូលចិត្ត

ស្លៀកខោពណ៌ខ្មៅ ជើងវែង ហើយចង្កេះលេខ៣១» ស្រាប់តែពេលគាត់ឃើញខោខ្មៅមួយមើលទៅស្អាត គាត់ក៏ហុចទៅអ្នកលក់ ហើយប្រាប់ថា «ខ្ញុំយកអាមួយនេះ» ដោយគិតថា ខោនោះលេខ៣១ តែតាមពិតខោនោះលេខ ៣០សោះ។

ក្នុងឧទាហរណ៍ទី៤ យើងឃើញថា៖

- កញ្ញា «ខ» បានភាន់ច្រឡំ (លក្ខខណ្ឌទី១)
- ការភាន់ច្រឡំអំពីទំហំខោ (ចំណុចសំខាន់ក្នុងការបង្កើតកិច្ចសន្យា ព្រោះចង់ទិញខោឱ្យត្រូវដណ្ដឹងទំហំលេខ៣១) (លក្ខខណ្ឌទី២)
- ភាគីអ្នកលក់អាចដឹងអំពីការភាន់ច្រឡំរបស់ «ខ» (លក្ខខណ្ឌទី៣)
- ភាគីអ្នកលក់បានដឹងអំពីទំហំដែល «ខ» ចង់បាន (លក្ខខណ្ឌទី៤)

*ដូចនេះ កញ្ញា «ខ» អាចលុបចោលកិច្ចសន្យាបាន។*

***<u>ស្ថានភាពទី៣៖</u>***

ស្ថានភាពនៃការភាន់ច្រឡំក្នុងកថាខណ្ឌនេះ មានលក្ខណៈខុសគ្នាពីស្ថានភាពទាំង២ ខាងលើ ព្រោះថាករណីនេះ ការភាន់ច្រឡំគឺកើតចេញពីភាគីទាំងសងខាងនៃកិច្ចសន្យា ដូចនេះភាគីអាចធ្វើការលុបចោលកិច្ចសន្យាបាន ប្រសិនបើភាគីទាំងសងខាងមានការភាន់ច្រឡំលើចំណុចសំខាន់ៗនៃកិច្ចសន្យា ឬចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។ អ្វីដែលគួរចាប់អារម្មណ៍នោះគឺ ភាគីដែលភាន់ច្រឡំអាចអះអាងលុបចោលកិច្ចសន្យាបាន ដោយមិនចាំបាច់ទាមទារឱ្យមានការបញ្ជាក់ថាភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ។ ត្រង់ចំណុចនេះ មិនមែនមានន័យថា ច្បាប់អនុញ្ញាតឱ្យលុបកិច្ចសន្យាដោយស្រួលនោះទេ ប៉ុន្តែវាសមហេតុសមផលដែលអាចលុបបាន ព្រោះថាភាគីទាំងសងខាងសុទ្ធតែមានការយល់ច្រឡំ ហើយបើយើងគិតទៅលើគោលការណ៍ព្រមព្រៀងនោះ គឺមិនមាននោះទេ ព្រោះឆន្ទៈរបស់ភាគីទាំងសងខាងមិនត្រូវគ្នា។

ចំពោះការលុបចោលកិច្ចសន្យាដោយហេតុនៃការភាន់ច្រឡំ មិនត្រឹមតែអាចអះអាងចំពោះភាគីម្ខាងទៀតប៉ុណ្ណោះទេ លើសពីនេះ ថែមទាំងអាចអះអាងចំពោះតតិយជនបានទៀតផង ក្នុងករណីដែលមានតតិយជនពាក់ព័ន្ធនឹងទំនាក់ទំនងផលប្រយោជន៍នៃកិច្ចសន្យា ដែលត្រូវបានលុបចោល។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់បានការពារតតិយជនដែលជាជនសុចរិត ហើយគ្មាន

កំហុស បានន័យថា ការលុបចោលកិច្ចសន្យានេះអាចអះអាងបានតែចំពោះភាគីប៉ុណ្ណោះ ក្នុងករណីដែលតតិយជនជាបុគ្គលដែលគ្មានគំនិតទុច្ចរិត ហើយថែមទាំងពុំមានកំហុសនៅក្នុងរឿងនេះ។[8]

លក្ខខណ្ឌដែលត្រូវបំពេញរួមមាន៖ [9] (១) ភាគីទាំងសងខាងមានការភាន់ច្រឡំ និង (២) ចំណុចដែលមានការភាន់ច្រឡំ គឺជាចំណុចសំខាន់នៃកិច្ចសន្យា ឬជាចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬជាចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។

***ឧទាហរណ៍ទី៥៖***

កញ្ញា «ក» បានទៅហាងលក់ម៉ូតូរបស់លោក «ខ» ក្នុងគោលបំណងទិញម៉ូតូ scoopy-i 2018។ គួរបញ្ជាក់ថាម៉ូតូ scoopy-i មាន២ប្រភេទគឺ ប្រភេទ urban team (1950$) និងប្រភេទ prestige (2150$) ដែលប្រភេទទាំង២នេះមានរាងរៅដូចគ្នាទាំងអស់ ខុសគ្នាតែពណ៌ និងតែមប៉ុណ្ណោះ។ កញ្ញា «ក» ចង់បាន scoopy-i 2018 ប្រភេទ urban team ប៉ុន្តែពេលរើសម៉ូតូក៏ចង្អុលចំប្រភេទ prestige ចំណែកអ្នកលក់បានលក់ក្នុងតម្លៃ 1950$។

ចំពោះឧទាហរណ៍នេះវិញ យើងឃើញថា៖

- ភាគីទាំងសងខាងមានការភាន់ច្រឡំ។ កញ្ញា «ក» យល់ច្រឡំលើប្រភេទម៉ូតូ ឯអ្នកលក់ «ខ» យល់ច្រឡំលើតម្លៃ (លក្ខខណ្ឌទី១)
- ការភាន់ច្រឡំលើប្រភេទ និងតម្លៃម៉ូតូ គឺជាចំណុចសំខាន់នៃកិច្ចសន្យា (លក្ខខណ្ឌទី២)

***ដូចនេះ ភាគីណាម្ខាងក៏អាចបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាបានដែរ។***

### ១.២.១.២ ការឆបោក

ការបង្ហាញឆន្ទៈដោយសារការឆបោក គឺសំដៅលើការបង្ហាញឆន្ទៈ ដែលមាននរណាម្នាក់ជាអ្នកបោកបញ្ឆោតអ្នកបង្ហាញឆន្ទៈឱ្យមានការភាន់ច្រឡំ ដូចជាការបន្លំ ការបោកប្រាស់ ការកុហក ឬប្រើប្រាស់កលល្បិចផ្សេងៗ ដែលធ្វើឱ្យអ្នកបង្ហាញឆន្ទៈបង្ហាញនូវឆន្ទៈដែលខុសពីឆន្ទៈពិតរបស់ខ្លួន។ ការឆបោក អាចត្រូវបានធ្វើឡើងដោយភាគីនៃកិច្ចសន្យា ឬកើតចេញពីតតិយជន។ ក្នុងករណីដែលភាគីម្ខាងជាអ្នកឆបោកភាគីម្ខាងទៀត នោះពិតជាសមហេតុសមផលណាស់ដែលអាចឱ្យភាគីដែលត្រូវបានឆបោកអះអាងលុបចោលកិច្ចសន្យា ព្រោះថាការបង្ហាញឆន្ទៈមានវិការៈ។ [10] ផ្ទុយទៅវិញ

[8] មាត្រា៣៤៦ កថាខណ្ឌ៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[9] មាត្រា៣៤៦ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[10] មាត្រា៣៤៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប្រសិនបើអ្នកឆបោកគឺជាតតិយជន មិនមែនជាភាគីនៃកិច្ចសន្យា អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានលុះត្រាតែភាគីម្ខាងទៀត អាចដឹង ឬបានដឹងអំពីការឆបោកនោះ បើមិនដូច្នោះទេ ពុំអាចធ្វើការលុបចោលបានឡើយ ព្រោះថា ប្រសិនបើភាគីម្ខាងទៀតមិនបានដឹងពីការឆបោកនោះទេ ហើយភាគីដែលត្រូវបានឆបោកដោយតតិយជនស្រាប់តែលុបចោលកិច្ចសន្យា នោះនឹងមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ដែលពុំដឹងរឿងអ្វីសោះ។[11]

យើងគួរគិតផងដែរ ចំពោះការឆបោកខ្លះដែលមានការប៉ះពាល់តិចតួចដល់ផលប្រយោជន៍របស់ភាគី ហើយដែលការឆបោកនោះត្រូវបានសង្គមទទួលស្គាល់ នោះអ្នកបង្ហាញឆន្ទៈមិនអាចលុបចោលកិច្ចសន្យាបានទេ ដូចជា អ្នកលក់ប្រាប់ថា ទំនិញនៅហាងរបស់គាត់មានគុណភាពល្អ អាហារនៅហាងរបស់គាត់ឈ្ងុយឆ្ងាញ់ជាងគេ ប្រភេទទំនិញដែលកំពុងពេញនិយម លក់ដាច់ជាងគេ ជាដើម។

លក្ខខណ្ឌនៃការឆបោក៖

(១) សកម្មភាពបោកបញ្ឆោត ឬបំភ្លៃការពិត

(២) ចេតនានៃការឆបោក

(៣) ការយល់ច្រឡំអង្គហេតុរបស់អ្នកបង្ហាញឆន្ទៈ និង

(៤) ការបង្ហាញឆន្ទៈដោយផ្អែកលើការយល់ច្រឡំអង្គហេតុ។

ចំពោះករណីការឆបោកដែលធ្វើឡើងដោយតតិយជន ត្រូវបំពេញលក្ខខណ្ឌមួយទៀតគឺ (៥) ភាគីម្ខាងទៀតនៃកិច្ចសន្យាអាចដឹង ឬបានដឹងអំពីការឆបោកនោះ។

***ឧទាហរណ៍ទី៦៖*** (ករណីការឆបោកធ្វើឡើងដោយភាគី)

អ្នកលក់ បានកុហកអ្នកទិញថា កាបូប MK (MICHAEL KORS) នៅហាងរបស់ខ្លួនជាផលិតផលសុទ្ធនាំមកពីសហរដ្ឋអាមេរិច ប៉ុន្តែតាមពិតទៅជាកាបូប MK ដែលផលិតនៅប្រទេសថៃ។ អ្នកទិញបានជឿថាពិតជាកាបូប MK ដែលផលិតនៅអាមេរិច ហើយបានយល់ព្រមទិញកាបូបនោះ។

ក្នុងករណីនេះយើងឃើញថា៖

- សកម្មភាពដែលអ្នកលក់បានកុហកអ្នកទិញពីប្រទេសដែលផលិតកាបូប ជាការឆបោកបំភ្លៃការពិត (លក្ខខណ្ឌទី១)
- អ្នកលក់មានចេតនាធ្វើឱ្យអ្នកទិញយល់ច្រឡំ (លក្ខខណ្ឌទី២)
- អ្នកបង្ហាញឆន្ទៈ (អ្នកទិញ) បានយល់ច្រឡំអង្គហេតុ កាបូបផលិតនៅប្រទេសថៃ ថាជាកាបូបផលិតនៅអាមេរិច ដោយសារការឆបោករបស់អ្នកលក់ (លក្ខខណ្ឌទី៣)

[11] មាត្រា៣៤៧ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- អ្នកទិញបង្ហាញឆន្ទៈយល់ព្រមទិញកាបូប ដោយផ្អែកលើការយល់ច្រឡំអង្គហេតុ ដោយសារមានការឆបោកពីអ្នកលក់ (លក្ខខណ្ឌទី៤)

*ដូចនេះ អ្នកទិញអាចលុបចោលកិច្ចសន្យាបានដោយយកមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ ដោយសារមានការឆបោករបស់អ្នកលក់។*

*ឧទាហរណ៍ទី៧៖* (ករណីការឆបោកធ្វើឡើងដោយតតិយជន)

យើងសូមលើកយកឧទាហរណ៍ដែលស្រដៀងនឹងឧទាហរណ៍ខាងលើដែរ។ អ្នកលក់ «ក» ជាម្ចាស់ហាងលក់កាបូប MK ដែលជាប្រ៊ែនរបស់ប្រទេសថៃ។ អតិថិជន «ខ» កំពុងដើរមើលកាបូប ដែលដាក់តាំងលក់នៅក្នុងហាងរបស់ «ក»។ បុគ្គលិកលក់ម្នាក់ «គ» បានប្រាប់ «ខ» ថាកាបូបនៅហាងនេះនាំចូលមកពីប្រទេសអាមេរិច ពេលនោះម្ចាស់ហាង «ក» ក៏នៅទីនោះដែរ។ «ខ» ជឿ និង បានទិញកាបូបនោះ។

ចំពោះករណីនេះវិញ យើងឃើញថា៖

- សកម្មភាពដែល «គ» (តតិយជន) បានកុហក «ខ» ពីប្រទេសដែលផលិតកាបូប ជាការឆបោកបំភ្លៃការពិត (លក្ខខណ្ឌទី១)
- «គ» មានចេតនាធ្វើឱ្យ «ខ» យល់ច្រឡំ (លក្ខខណ្ឌទី២)
- អ្នកទិញ «ខ» បានយល់ច្រឡំអង្គហេតុ កាបូបផលិតនៅប្រទេសថៃ ថាជាកាបូបផលិតនៅអាមេរិចដោយសារការឆបោករបស់ «គ» (លក្ខខណ្ឌទី៣)
- អ្នកទិញ «ខ» បង្ហាញឆន្ទៈយល់ព្រមទិញកាបូបដោយផ្អែកលើការយល់ច្រឡំអង្គហេតុ ដោយសារមានការឆបោកពីអ្នកលក់ (លក្ខខណ្ឌទី៤)
- ភាគីម្ខាងទៀត «ក» អាចដឹង ឬបានដឹងអំពីការឆបោក ព្រោះពេលនោះគាត់ក៏នៅទីនោះដែរ (លក្ខខណ្ឌទី៥)

*ដូចនេះ អ្នកទិញ «ខ» អាចលុបចោលកិច្ចសន្យាបាន ដោយយកមូលហេតុនៃការបង្ហាញឆន្ទៈមានវិការៈដោយសារមានការឆបោកពីតតិយជន។*

ការលុបចោលកិច្ចសន្យាដោយហេតុនៃការឆបោក មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសបានទេ។[12]

[12] មាត្រា៣៤៧ កថាខណ្ឌ៣ វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.២.១.៣ ព័ត៌មានមិនពិត

ព័ត៌មានមិនពិត សំដៅលើព័ត៌មានក្លែងក្លាយ ការណ៍មិនពិត ហេតុដែលខុសពីការពិត -ល- ដែលភាគីម្ខាងបានកុហកទៅភាគីម្ខាងទៀតនៃកិច្ចសន្យា។ ត្រង់នេះ មានន័យថា អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈព្រោះខ្លួនជឿជាក់ថាព័ត៌មានដែលខ្លួនបានទទួលនោះជាការពិត ហើយប្រសិនបើខ្លួនដឹងថា នេះមិនមែនជាព័ត៌មានដែលពិត នោះខ្លួនពិតជាពុំបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យានោះឡើយ។ ករណីដូចបានរៀបរាប់នេះ ភាគីដែលបង្ហាញឆន្ទៈដោយសារទទួលបានព័ត៌មានមិនពិត អាចលុបចោលកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[13] លើសពីនេះ អ្នកបង្ហាញឆន្ទៈក៏អាចទាមទារសំណងការខូចខាតពីភាគីដែលផ្តល់ព័ត៌មានមិនពិតបានផងដែរ ក្នុងករណីដែលបុគ្គលនេះជាជនមានកំហុស (មាត្រា៣៤៨ កថាខណ្ឌទី២ នៃក្រម)។

លក្ខខណ្ឌនៃព័ត៌មានមិនពិត៖

(១) ការបង្ហាញព័ត៌មានមិនពិតដោយភាគីនៃកិច្ចសន្យា

(២) ពុំចាំបាច់គិតពីចេតនារបស់អ្នកបង្ហាញព័ត៌មានមិនពិត

(៣) ភាគីយល់ច្រឡំអង្គហេតុ និង

(៤) ភាគីនឹងមិនបង្ហាញឆន្ទៈទេ បើមិនមានការយល់ច្រឡំ។

***ឧទាហរណ៍ទី៨៖*** លោក «ច» បានទៅហាងលក់ទូរស័ព្ទមួយកន្លែង ដើម្បីទិញទូរស័ព្ទមួយគ្រឿងដែលមិនចូលទឹក ដោយសារទូរស័ព្ទរបស់គាត់ទើបតែខូច ហើយណាមួយខែភ្លៀងទៀត។ អ្នកលក់បានណែនាំទូរស័ព្ទមួយទៅគាត់ថា «នេះជាម៉ូតទើបចេញថ្មី មានប្រព័ន្ធការពារមិនឱ្យចូលទឹក (Waterproof) និងមានការធានារយៈពេលមួយឆ្នាំ» លោក «ច» គិតមួយសន្ទុះ រួចក៏ចរចារតម្លៃ និងបានប្រាប់ថា «បើអត់ចូលទឹកមែន ខ្ញុំទិញ»។ នៅតាមផ្លូវទៅផ្ទះ ស្រាប់តែមានភ្លៀងធ្លាក់ ហើយពេលទៅដល់ផ្ទះ ទូរស័ព្ទគាត់ចូលទឹកខូចប្រើលែងកើត។ គាត់ចង់ធ្វើការលុបចោលកិច្ចសន្យា។

បើគិតពីលក្ខខណ្ឌនៃព័ត៌មានមិនពិត យើងឃើញថា៖

- អ្នកលក់ទូរស័ព្ទបានប្រាប់ព័ត៌មានមិនពិតទាក់ទងនឹងទូរស័ព្ទទៅលោក «ក» ថាជាទូរស័ព្ទមានប្រព័ន្ធការពារពីការចូលទឹក (លក្ខខណ្ឌទី១)
- ភាពមានចេតនា ឬអចេតនា នៃអ្នកបង្ហាញព័ត៌មានមិនពិត ពុំទាមទារឱ្យបញ្ជាក់នោះទេ (លក្ខខណ្ឌទី២)

[13] មាត្រា៣៤៨ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- លោក «ច» មានការយល់ច្រឡំថាជាទូរស័ព្ទដែលធន់នឹងទឹកដោយសារការប្រាប់ព័ត៌មានមិនពិតរបស់ភាគីអ្នកលក់ (លក្ខខណ្ឌទី៣)
- លោក «ច» នឹងមិនយល់ព្រមទិញទូរស័ព្ទមួយនោះទេ បើគាត់មិនមានការយល់ច្រឡំដូចក្នុងលក្ខខណ្ឌទី៣ (លក្ខខណ្ឌទី៤)

*ដូចនេះ លោក «ច» អាចលុបចោលកិច្ចសន្យាលក់ទិញទូរស័ព្ទបាន ដោយយកមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ ដោយសារមានការផ្ដល់នូវព័ត៌មានមិនពិត។*

ដូចគ្នាទៅនឹងការភាន់ច្រឡំ និងការឆបោកដែរ ការលុបចោលកិច្ចសន្យាដោយសារព័ត៌មានមិនពិតមិនអាចអះអាងចំពោះតតិយជនសុចរិត និងគ្មានកំហុសបានឡើយ។

### ១.២.១.៤ ការរំលោភបំពានលើស្ថានភាព

នៅពេលដែលបុគ្គលណាម្នាក់បានបង្ហាញឆន្ទៈ ខណៈដែលខ្លួនស្ថិតក្រោមសម្ពាធ ឬឥទ្ធិពលរបស់ភាគីម្ខាងទៀត ឬភាគីម្ខាងទៀតមានអាទិភាពជាងខ្លួន កិច្ចសន្យានោះមិនគួរឱ្យមានសុពលភាពឡើយ ព្រោះភាគីមិនបានបង្ហាញឆន្ទៈដោយសេរី និងពិតប្រាកដនោះទេ ពោលគឺមានការរំលោភលើស្ថានភាពដែលភាគីមិនអាចតវ៉ាបាន ទើបខ្លួនបង្ហាញឆន្ទៈ ដែលតាមពិតទៅ ឆន្ទៈនោះមិនមែនជាបំណងពិតរបស់អ្នកបង្ហាញឆន្ទៈឡើយ។

មាត្រា៣៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា « នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យា បានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថាការង្ហាញឆន្ទៈនោះមានវិការៈ»។

យោងតាមមាត្រាខាងលើ ភាគីអាចលុបចោលកិច្ចសន្យាដោយផ្អែកលើមូលហេតុមានការរំលោភលើស្ថានភាព លុះត្រាតែបានបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

(១) ភាគីម្ខាងមានឋានៈ ឬស្ថានភាពផ្សេងទៀត ដែលមានឥទ្ធិពលជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម

(២) មានការប្រើប្រាស់ដោយមិនត្រឹមត្រូវនូវឋានៈ ឬស្ថានភាព ពីសំណាក់ភាគីដែលមានឥទ្ធិពលជាងនោះ

(៣) ចេតនារបស់អ្នករំលោភបំពានលើស្ថានភាព និង

(៤) ភាគីម្ខាងទៀត មិនអាចប្រឆាំងតបតបាន ហើយធ្វើការបង្ហាញឆន្ទៈ។

***ឧទាហរណ៍ទី៩៖*** លោក «ក» ជាអ្នកគ្រប់គ្រងទូទៅនៅក្រុមហ៊ុនមួយដែលលោក «ខ» ធ្វើការ។ លោក «ក» បានដាក់សំណើទិញដីរបស់លោក «ខ» ស្របពេលដែលក្រុមហ៊ុនមានគម្រោងកាត់បន្ថយបុគ្គលិក។ លោក «ខ» មិនចង់លក់ដីនោះទេ ព្រោះនេះជាកេរពីម្ដាយរបស់គាត់ ប៉ុន្តែដោយសារតែខ្លាចលោក «ក» បញ្ឈប់ពីការងារ គាត់ក៏បានយល់ព្រមលក់ដីនោះក្នុងតម្លៃទីផ្សារ។ តើលោក «ខ» អាចលុបចោលកិច្ចសន្យានេះបានដែរ ឬទេ?

ដើម្បីអាចដឹងថាគាត់អាចលុបបាន ឬមិនបាន លុះត្រាតែពិនិត្យមើលលក្ខខណ្ឌដូចខាងក្រោម៖

- លោក «ក» មានឋានៈដែលមានឥទ្ធិពលជាងលោក «ខ» (លោក «ក» ជាអ្នកគ្រប់គ្រង ឯលោក «ខ» ត្រឹមតែជាបុគ្គលិក) ហើយលោក «ក» ក៏មានស្ថានភាពដែលមានអាទិភាពជាងលោក «ខ» ផងដែរ (គាត់មានសិទ្ធិកាត់បន្ថយបុគ្គលិក) (លក្ខខណ្ឌទី១)
- លោក «ក» បានប្រើប្រាស់ស្ថានភាពដែលមានអាទិភាពដោយមិនត្រឹមត្រូវ ពោលគឺការដាក់សំណើទិញដីរបស់ភាគីម្ខាងទៀត ក្នុងពេលដែលក្រុមហ៊ុនចង់កាត់បន្ថយបុគ្គលិក (លក្ខខណ្ឌទី២)
- លោក «ក» មានចេតនាធ្វើឱ្យលោក «ខ» យល់ព្រមលក់ ដោយសារខ្លាចត្រូវបានបញ្ឈប់ពីការងារ (លក្ខខណ្ឌទី៣)
- បើគិតពីស្ថានភាពនេះ លោក «ខ» មិនអាចប្រឆាំងតបតបានទេ ព្រោះខ្លាចបាត់បង់ការងារ ទើបបង្ហាញឆន្ទៈយល់ព្រមលក់ដីដែលជាកេរម្ដាយ ទោះមិនចង់ក៏ដោយ (លក្ខខណ្ឌទី៤)

*ដូចនេះ លោក «ខ» អាចធ្វើការលុបចោលកិច្ចសន្យាលក់ទិញដីនេះបាន ដោយយកមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ ដោយសារករណីរំលោភបំពានលើស្ថានភាព។*

### ១.២.១.៥ ការគម្រាមកំហែង

ការគម្រាមកំហែង គឺជាការប្រើប្រាស់ពាក្យសម្ដី ឬកាយវិការជាអាទិ៍ ដើម្បីបង្ខំឱ្យនរណាម្នាក់ធ្វើអ្វីមួយទៅតាមការចង់បានរបស់ខ្លួន។ កិច្ចសន្យាមួយដែលបង្កើតឡើង ដោយភាគីម្ខាងបានគម្រាមកំហែងភាគីម្ខាងទៀតឱ្យបង្ហាញឆន្ទៈ កិច្ចសន្យានោះមិនគួរបន្តឱ្យមានសុពលភាពឡើយ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តួយ៉ាងក្នុងករណីនេះ យើងឃើញថា ភាគីមិនបានបង្ហាញឆន្ទៈដោយស្ម័គ្រចិត្តឡើយ គាត់បានបង្ហាញឆន្ទៈព្រោះតែខ្លាចការគម្រាមកំហែងរបស់ភាគីម្ខាងទៀត។ គួរបញ្ជាក់ផងដែរថា ការគម្រាមកំហែងអាចត្រូវបានធ្វើឡើងដោយភាគីផ្ទាល់ ឬដោយតតិយជន ទៅលើភាគីម្ខាងទៀត ឬសាច់ញាតិរបស់ភាគីតាមរយៈរូបភាពជាពាក្យសម្ដី ឬការប្រើប្រាស់កាយវិការ

ផ្សេងៗ។ ភាគីដែលបង្ហាញឆន្ទៈដោយមានការគម្រាមកំហែងដូចបានរៀបរាប់ខាងលើ អាចលុបចោលកិច្ចសន្យាបាន។[14] ចំពោះការគម្រាមកំហែងពីសំណាក់តតិយជន ភាគីដែលបង្ហាញឆន្ទៈដោយការគម្រាមកំហែងអាចលុបចោលកិច្ចសន្យាបាន ទោះបីជាភាគីម្ខាងទៀតពុំបានដឹងពីការគម្រាមកំហែងក៏ដោយ ព្រោះថាការគម្រាមកំហែងមានលក្ខណៈធ្ងន់ធ្ងរ និងគ្រោះថ្នាក់។ ឆ្លើយតបទៅនឹងចំណុចនេះ អាចនឹងមានការលើកឡើងថា ការអនុញ្ញាតបែបនេះ នឹងធ្វើឱ្យមានអស្ថេរភាពដល់កិច្ចការជំនួញ និងអយុត្តិធម៌ចំពោះភាគីម្ខាងទៀត ទោះបីជាយ៉ាងណាក៏ដោយ ភាគីម្ខាងទៀតអាចទាមទារសំណងការខូចខាតពីតតិយជនបានតាមអំពើអនីត្យានុកូល។

លក្ខខណ្ឌនៃការគម្រាមកំហែង៖

(១) សកម្មភាពគម្រាមកំហែងដោយខុសច្បាប់ ដោយភាគី ឬតតិយជន

(២) ចេតនានៃការគម្រាមកំហែង

(៣) អ្នកបង្ហាញឆន្ទៈមានការភ័យខ្លាចអំពើគំរាមនោះ និង

(៤) ការបង្ហាញឆន្ទៈដោយសារការគម្រាមកំហែង។

***ឧទាហរណ៍ទី១០៖*** សូមលើកយកឧទាហរណ៍ទាក់ទងនឹងស្ថានភាពខាងលើដដែល ប៉ុន្តែមានបន្ថែមអង្គហេតុត្រង់ថា នៅពេលលោក «ក» ដាក់សំណើទិញដីពីលោក «ខ» គាត់បាននិយាយថា «ខ្ញុំចង់ទិញផ្ទះរបស់អ្នកឯង បើមិនលក់ទេ ប្រយ័ត្នខ្ញុំបញ្ឈប់ពីការងារ»។

ដើម្បីអាចលុបចោលកិច្ចសន្យា ដោយយកមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ ដោយសារមានការគម្រាមកំហែង ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- លោក «ក» បានធ្វើការគម្រាមកំហែងដោយខុសច្បាប់តាមរយៈការប្រើពាក្យសំដី (លក្ខខណ្ឌទី១)
- ការប្រើប្រាស់ពាក្យសំដីរបស់លោក «ក» បង្ហាញឱ្យឃើញច្បាស់ថា គាត់មានចេតនាគម្រាមកំហែងលោក «ខ» ឱ្យលក់ដីឱ្យខ្លួន (លក្ខខណ្ឌទី២)
- លោក «ខ» មានការភ័យខ្លាចនូវអំពើគម្រាមកំហែងនោះ គឺខ្លាចគេបញ្ឈប់ពីការងារ (លក្ខខណ្ឌទី៣)
- ដោយសារមានការគម្រាមកំហែងពីលោក «ក» ទើបលោក «ខ» បង្ហាញ ឆន្ទៈលក់ដី (លក្ខខណ្ឌទី៤)

[14] មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

***ដូចនេះ លោក «ខ» អាចអះអាងលុបចោលកិច្ចសន្យាបាន ដោយយកមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ ដោយសារមានការគម្រាមកំហែង។***

ករណីខាងលើនេះ គឺជាការគម្រាមកំហែងធ្វើឡើងពីសំណាក់ភាគីនៃកិច្ចសន្យា ខាងក្រោមនេះ សូមលើកយកករណីដែលតតិយជនជាអ្នកគម្រាមកំហែងវិញម្តង។

***ឧទាហរណ៍ទី១១៖*** លោក «ក» បានដាក់សំណើទិញផ្ទះលោក «ខ»។ ពីរបីថ្ងៃក្រោយមក មានតតិយជន «គ» ខលទៅលោក «ខ» ហើយនិយាយថា «បើចង់បានសុខ ប្រញាប់យល់ព្រមលក់ផ្ទះឱ្យលោក «ក» ទៅ»។ ដោយភ័យខ្លាច និងបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន លោក «ខ» ក៏យល់ព្រមលក់ផ្ទះឱ្យទៅលោក «ក»។ លោក «ក» ស្រលាញ់ផ្ទះនោះណាស់ ដោយសារជាផ្ទះដែលគាត់ខិតខំរកស៊ីជាមួយប្រពន្ធទម្រាំបានផ្ទះមួយនេះ។ គាត់ចង់លុបចោលកិច្ចសន្យា។

ដើម្បីអាចលុបបាន យើងត្រូវពិនិត្យមើលថាតើលក្ខខណ្ឌត្រូវបានបំពេញគ្រប់ឬទេ?

- សកម្មភាពខលទៅគម្រាមលោក «ខ» ឱ្យលក់ផ្ទះ ពីសំណាក់តតិយជន «គ» ដែលជាអំពើខុសច្បាប់ (លក្ខខណ្ឌទី១)
- តតិយជន «គ» មានចេតនាគម្រាមកំហែងលោក «ខ» ឱ្យលក់ផ្ទះ (លក្ខខណ្ឌទី២)
- លោក «ខ» មានការភ័យខ្លាចពាក្យសម្តីគម្រាមកំហែងនោះ (លក្ខខណ្ឌទី៣)
- ការបង្ហាញឆន្ទៈរបស់លោក «ខ» កើតឡើងដោយសារខ្លួនត្រូវបានតតិយជនគម្រាមកំហែង (លក្ខខណ្ឌទី៤)

***ដូចនេះ លោក «ខ» អាចធ្វើការលុបចោលកិច្ចសន្យាលក់ទិញផ្ទះនេះបាន ដោយយកមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ ដោយសារមានអំពើគម្រាមកំហែង។ គួរកត់សម្គាល់ថា ទោះបីជាលោក «ក» ដែលជាភាគីម្ខាងទៀតបានដឹង ឬមិនបានដឹងអំពីការគម្រាមកំហែងរបស់តតិយជន «គ» ក៏លោក «ខ» នៅតែអាចអះអាងលុបចោលកិច្ចសន្យាបាន ព្រោះថាការគម្រាមកំហែងមានលក្ខណៈធ្ងន់ធ្ងរ ហើយធ្វើឱ្យអ្នកត្រូវបានគេគម្រាមកំហែងមានការភ័យខ្លាចយ៉ាងខ្លាំង។ ចំពោះភាគីម្ខាងទៀត (លោក «ក») អាចទាមទារសំណងការខូចខាតពីតតិយជននោះតាមអំពើអនីត្យានុកូល។***

យើងពុំឃើញមានបញ្ញត្តិការពារតតិយជនសុចរិត និងគ្មានកំហុស នៅក្នុងក្រមរដ្ឋប្បវេណីទេ ចំពោះរឿងគម្រាមកំហែងនេះ។ ដូចនេះ យើងអាចស្វែងយល់ពីគោលគំនិតច្បាប់បានថា ការលុបចោលកិច្ចសន្យាដោយសារការបង្ហាញឆន្ទៈមានវិការៈ ព្រោះមានអំពើគម្រាមកំហែងអាចអះអាងបានចំពោះតតិយជនគ្រប់ប្រភេទទាំងអស់ មិនថាសុចរិត ឬទុច្ចរិត មានកំហុស ឬគ្មានកំហុសឡើយ។

### ១.២.១.៦ អំពីការកេងចំណេញហួសហេតុ

នៅក្នុងកិច្ចការជំនួញ ជាធម្មតាទេដែលភាគីនៃកិច្ចសន្យាតែងតែរំពឹងចង់បានប្រាក់ចំណេញខ្ពស់ ប៉ុន្តែប្រសិនបើភាគីណាម្ខាងនៃកិច្ចសន្យា បានឆ្លៀតឱកាសក្នុងការកេងចំណេញយ៉ាងហួសហេតុពីភាគីម្ខាងទៀត នោះឃើញថាភាគីម្ខាងទៀតគួរឱ្យអាណិតណាស់។

ដើម្បីអាចលុបចោលកិច្ចសន្យា ដោយយកមូលហេតុនៃការកេងចំណេញហួសហេតុបានតម្រូវឱ្យមានការបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖[15]

(១) ភាគីម្ខាងកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះការពិសោធន៍ ដែលជះឥទ្ធិពលដល់ការបង្ហាញឆន្ទៈ

(២) ភាគីម្ខាងទៀតបានឆ្លៀតឱកាសកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យា

(៣) ឆន្ទៈនៃអំពើកេងចំណេញហួសហេតុ

(៥) អ្នកធ្វើអំពើកេងចំណេញហួសហេតុ បានទទួលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់។

***ឧទាហរណ៍ទី១២៖*** មីង «ស» រើសបានចិញ្ចៀនមួយវង់ ហើយគាត់បានយកទៅលក់នៅហាងមាសពេជ្រមួយកន្លែង ក្រោយពីពិនិត្យមើលហើយម្ចាស់ហាងបានប្រាប់ថា ជាមាស-ស និងត្បូងទឹកធម្មតា ហើយឱ្យតម្លៃ ៥០០ដុល្លារ។ មីង «ស» ក៏យល់ព្រមលក់។ តាមការពិតចិញ្ចៀននោះធ្វើពីមាស-ស និងដាំត្បូងពេជ្រ ដែលគិតជាតម្លៃប្រហែល ៣ ០០០ដុល្លារឯណោះ។

ករណីនេះ ជាការកេងចំណេញហួសហេតុព្រោះ៖

- មីង «ស» ជាជនដែលខ្វះបទពិសោធន៍ និងមិនចេះមើលពីប្រភេទត្បូងនោះទេ (លក្ខខណ្ឌទី១)
- ម្ចាស់ហាងមាសពេជ្រ បានឆ្លៀតឱកាសកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានេះ (លក្ខខណ្ឌទី២)
- ឆន្ទៈនៃការកេងចំណេញហួសហេតុ ស្តែងចេញតាមរយៈការមិនប្រាប់ថាចិញ្ចៀននោះដាំពេជ្រ ហើយបានឱ្យតម្លៃទាបយ៉ាងខ្លាំង (លក្ខខណ្ឌទី៣)
- ម្ចាស់ហាងមាសពេជ្របានទទួលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ពីកិច្ចសន្យានេះ (លក្ខខណ្ឌទី៤)

***ដូចនេះ មីង «ស» អាចលុបចោលកិច្ចសន្យាបាន ផ្អែកលើវិការៈនៃការបង្ហាញឆន្ទៈ ដោយសារមានការកេងចំណេញហួសហេតុ។***

[15] មាត្រា៣៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.២.២ ការខ្វះសមត្ថភាពរបស់ភាគី

ជាគោលការណ៍ រូបវន្តបុគ្គលទាំងឡាយ នៅពេលដែលមានរូបរាង និងធ្វើទំនាក់ទំនងក្នុងសង្គម នឹងបង្កើតជាសិទ្ធិ និងកាតព្វកិច្ច ដែលជាលក្ខខណ្ឌតម្រូវតាមច្បាប់ ហើយដើម្បីអាចឱ្យសកម្មភាពនោះបង្កើតឡើងនូវសិទ្ធិ និងកាតព្វកិច្ច លុះត្រាតែច្បាប់ទទួលស្គាល់ថា ជាបុគ្គលមានសមត្ថភាព។ សមត្ថភាពតាមផ្លូវច្បាប់ ដែលមានកំណត់ដោយនីតិរដ្ឋប្បវេណីមាន៣ គឺ សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងនោះ ការលុបចោលកិច្ចសន្យាដោយមូលហេតុខ្វះសមត្ថភាពរបស់ភាគី មានតែ ២ប៉ុណ្ណោះ គឺ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។

#### ១.២.២.១ ការខ្វះសមត្ថភាពខាងឆន្ទៈ

សមត្ថភាពខាងឆន្ទៈ គឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ឆន្ទៈរបស់ភាគីពិតជាចាំបាច់ណាស់ក្នុងការបង្កើតកិច្ចសន្យា ឬដែលនាំឱ្យមានការបង្កើតកិច្ចសន្យា ហេតុនេះកិច្ចសន្យាដែលភាគីបានបង្កើតឡើងនៅពេលខ្លួនខ្វះសមត្ថភាពខាងឆន្ទៈ អាចលុបចោលបាន។[16]

ជនដែលខ្វះសមត្ថភាពខាងឆន្ទៈ គឺជាជនដែលមានស្ថានភាពដូចមានចែងក្នុងមាត្រា១៤ នៃក្រមរដ្ឋប្បវេណី ដែលអាចជានីតិជនដែលស្ថិតក្នុងស្ថានភាពស្រវឹង មនុស្សចាស់ជរា (វង្វេង ភ្លេចភ្លាំងច្រើន) ជាដើម។

ឧទាហរណ៍៖ លោក «ក» បានធ្វើកិច្ចសន្យាប្រទានកម្មទូរស័ព្ទ I-Phone X របស់ខ្លួនឱ្យទៅមិត្តភក្តិរបស់គាត់ គឺលោក «ខ» នៅពេលដែលគាត់កំពុងស្រវឹងស្រាជោគជាំ។

ក្នុងឧទាហរណ៍ខាងលើនេះ លោក «ក» បានធ្វើកិច្ចសន្យានៅពេលដែលខ្លួនខ្វះសមត្ថភាពខាងឆន្ទៈ ដូចនេះគាត់អាចលុបចោលកិច្ចសន្យានេះបាន។

#### ១.២.២.២ ការខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព

សមត្ថភាពក្នុងការធ្វើសកម្មភាព ជាសមត្ថភាពដែលអាចធ្វើសកម្មភាពដោយមានសុពលភាពពេញលេញ។ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់បុគ្គល ៣ប្រភេទ ជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពដែលរួមមាន៖ អនីតិជន ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ ពោលគឺជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើកិច្ចសន្យាសុពល។

[16] មាត្រា១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**ក. អនីតិជន**

អនីតិជន សំដៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ។[17] អនីតិជន ត្រូវស្ថិតនៅក្រោមរបប អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដូចនេះ សកម្មភាពដែលអនីតិជន ធ្វើដោយពុំមានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន។[18] អ្នកមានសិទ្ធិអំណាចមេបាអាចជាឪពុកម្តាយ ឪពុក ឬម្តាយ ឬឪពុកម្តាយ ចិញ្ចឹម។[19] ចំណែកឯអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើមនៅពេលដែលគ្មានអ្នកអនុវត្ត សិទ្ធិអំណាចមេបាសម្រាប់អនីតិជន។ [20] ប្រព័ន្ធនេះបង្កើតឡើងគឺដើម្បីការពារអនីតិជន ព្រោះថា កម្រិតនៃការយល់ដឹង ឬផ្នែកបញ្ញាស្មារតីរបស់អនីតិជន គឺពុំទាន់ពេញលេញ ដែលអាចនាំឱ្យខ្លួន បង្កើតកិច្ចសន្យាណាមួយដែលធ្វើឱ្យខាតបង់ប្រយោជន៍របស់អនីតិជន។ ទោះបីជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាការកំណត់អាយុនីតិភាពប៉ុណ្ណោះ ដែលមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេស មួយ ហើយពិតជាក់ស្តែង អនីតិជនមិនប្រាកដថាសុទ្ធតែមានការយល់ដឹងនៅមានកម្រិតនោះទេ ដូច្នេះហើយ ក្រមរដ្ឋប្បវេណីក៏បានលើកលែងនូវសកម្មភាពមួយចំនួន ដែលអនីតិជនអាចធ្វើបាន ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់កំណត់ដែលរួមមាន៖ សកម្មភាពដែល ទទួលសិទ្ធិ ការឱ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ពោលគឺ អាចធ្វើកិច្ចសន្យាដោយមានសុពលភាពពេញលេញ។ សូមលើកយកឧទាហរណ៍មួយចំនួនដូច ខាងក្រោម៖

***ឧទាហរណ៍ទី១៖*** អនីតិជន «ក» អាយុ១៣ឆ្នាំ បានធ្វើកិច្ចសន្យាលក់ទិញកង់ដែលមានតម្លៃ ២៥០ ០០០រៀល ជាមួយម្ចាស់ហាងលក់កង់មួយកន្លែង។ ក្រោយមក ឪពុកម្តាយរបស់អនីតិជន «ក» បានដឹង និងចង់លុបចោលកិច្ចសន្យា។

ក្នុងករណីនេះ ឪពុកម្តាយរបស់អនីតិជន «ក» អាចបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាបាន ដោយយកមូលហេតុខ្វះសមត្ថភាពរបស់អនីតិជន «ក» ហើយឪពុកម្តាយជាអ្នកមានសិទ្ធិអំណាច មេបារបស់ «ក»។

[17] មាត្រា១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[18] មាត្រា១៨ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[19] មាត្រា១០៣៥-១០៣៦, ១០៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[20] មាត្រា១០៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

***ឧទាហរណ៍ទី២៖*** ករណីទទួលសិទ្ធិ

«ក» ជាអនីតិជន។ «ច» ជាជីតារបស់ «ក» មានភាគហ៊ុនចំនួន ៣០% នៅក្នុងក្រុមហ៊ុនមួយ។ គាត់បានធ្វើប្រទានកម្មភាគហ៊ុនរបស់គាត់១០%ដែលមានក្នុងក្រុមហ៊ុននោះឱ្យទៅ«ក»។ក្នុងករណីនេះ «ក» នឹងក្លាយជាម្ចាស់កម្មសិទ្ធិលើភាគហ៊ុន ១០% នោះបើ «ក» យល់ព្រមទទួលយក។ ហើយ «ក» អាចយល់ព្រមទទួលយកភាគហ៊ុននោះបានដោយខ្លួនឯង ដោយមិនចាំបាច់ទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបារបស់ «ក» ទេ។ ដូចនេះ ការបង្ហាញឆន្ទៈរបស់ «ក» មានសុពលភាព។

***ឧទាហរណ៍ទី៣៖*** ករណីការឱ្យរួចផុតពីកាតព្វកិច្ច

«ក» មានអាយុ១៦ឆ្នាំ ជាសន្តតិជនតែម្នាក់របស់ «គ»។ មតិកជាទ្រព្យសកម្មរបស់ "គ" មានឡានមួយគ្រឿង ផ្ទះមួយល្វែង។ ចំណែកទ្រព្យអកម្ម គឺ «គ» បានជំពាក់បំណុល «ខ» ដែលជាបងប្រុសរបស់ខ្លួនចំនួន ៥០០ដុល្លារអាមេរិក។ «ប» ត្រូវបានតុលាការចាត់តាំងឱ្យធ្វើជាអ្នកអាណាព្យាបាលសម្រាប់ «ក» ។ «ខ» បានសម្រេចចិត្តមិនទាមទារយកបំណុលដែល «គ» បានខ្ចីពីខ្លួនវិញទេ ព្រោះយល់ថា «ក» ជាក្មួយរបស់ខ្លួន។

ករណីបែបនេះ គឺជាការលើកលែងឱ្យរួចផុតពីកាតព្វកិច្ច និងមិនចាំបាច់មានការយល់ព្រមពី «ប» ដែលជាអ្នកអាណាព្យាបាលសម្រាប់ «ក» ទេ។

**ឧទាហរណ៍ទី៤៖** ករណីទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ

«ក» ជាក្មេងអាយុ ១២ ឆ្នាំ រស់នៅជាមួយឪពុកម្តាយ។ ឪពុកម្តាយរបស់ «ក» បានឱ្យប្រាក់ទៅ «ក» ចំនួន ៥ ០០០រៀល សម្រាប់ចាយវាយនៅសាលារៀន។ «ក» អាចយកលុយនោះ ទៅទិញរបស់ញ៉ាំដែលគេចង់ញ៉ាំដូចជា៖ ការ៉េម ឬ នំផ្សេងៗ ដោយមិនចាំបាច់ទៅសុំការអនុញ្ញាតពីឪពុកម្តាយរបស់គេសិនទេ។ កិច្ចសន្យាដែលកុមារ«ក» ធ្វើកិច្ចសន្យាជាមួយអ្នកលក់ការ៉េម ឬអ្នកលក់នំ ជាកិច្ចសន្យាសុពលមានសុពលភាព ទោះបីជាកុមារ «ក» ស្ថិតក្នុងប្រភេទនៃជនដែលត្រូវបានកម្រិតសមត្ថភាពក៏ដោយ ព្រោះថាសកម្មភាពនេះ គឺទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃតែប៉ុណ្ណោះ។

ទន្ទឹមនឹងនេះ អនីតិជនក៏អាចធ្វើកិច្ចសន្យាសុពលពេញលេញបានផងដែរ ក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលបានផ្តល់ទ្រព្យសម្បត្តិ និងអនុញ្ញាតឱ្យចាត់ចែងក្នុងទំហំនៃគោលបំណងដែលបានកំណត់ ឬទោះបីមិនបានកំណត់ក៏ដោយ ដូចមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ យ៉ាងដូច្នេះថា «អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណងក្នុងទំហំនៃគោលបំណងនេះបាន។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យ

សម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ»។[21] ឧទាហរណ៍៖ សំ ជាអនីតិជនអាយុ ៩ឆ្នាំ ម្ដាយរបស់សំ បានឱ្យប្រាក់ទៅសំ ២០ ០០០រៀល ក្នុងនោះ ១៥ ០០០រៀល សម្រាប់ទិញសៀវភៅ និងសម្ភារសិក្សា ចំណែក ៥០០០រៀលទៀត មិនបានកំណត់ថាសម្រាប់ប្រើធ្វើអ្វីឡើយ។ ករណីនេះ កិច្ចសន្យាដែលសំបានបង្កើតក្នុងការទិញសៀវភៅ និងសម្ភារសិក្សាដែលមានតម្លៃ ១៥ ០០០រៀល ជាកិច្ចសន្យាសុពល ចំណែកប្រាក់ដែលនៅសល់ សំអាចចាត់ចែងដោយឯករាជ្យក្នុងទំហំដែលអាចបង់បានដោយប្រាក់ ៥ ០០០រៀលនោះ។

គួរបញ្ជាក់ផងដែរថា អនីតិជនក៏ត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្មដោយឯករាជ្យបានដែរ ដោយបានទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដូចមានបញ្ជាក់លម្អិតខាងក្រោម។

ក្នុងករណីដែលមានការទទួលស្គាល់ពីអាណាព្យាបាល (អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ឱ្យប្រកបអាជីវកម្មដោយឯករាជ្យបាន (មាត្រា១០៥៦ និង១០៧៩) ទោះបីជាអនីតិជនក៏ដោយ ក៏មានសមត្ថភាពក្នុងកាធ្វើកិច្ចសន្យាចាំបាច់សម្រាប់អាជីវកម្មនោះបានដែរ។ ប្រសិនជាមានការអនុញ្ញាតឱ្យប្រកបអាជីវកម្មដោយឯករាជ្យ តែរាល់ពេលទិញទំនិញចូល ឬពេលជួលបុគ្គលិកជាដើម សុទ្ធតែត្រូវទទួលការយល់ព្រមពីអ្នកអាណាព្យាបាល ការអនុញ្ញាតឱ្យប្រកបអាជីវកម្មមិនសូវមានន័យទៅវិញ។

ប្រសិនបើអ្នកមានអំណាចមេបាជាដើម បានអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្ម ដោយយល់ឃើញថា មានភាពចាស់ទុំដែរ ប៉ុន្តែជាការច្រឡំថា អនីតិជនបែរជាយកដើមទុនសម្រាប់ការរកទទួលទានទៅលេងល្បែងស៊ីសង ឬទិញតែទំនិញដែលលក់មិនដាច់ ហើយខាតរាល់ដងជាដើម ក្នុងករណីនេះ អ្នកមានអំណាចមេបាជាដើមនោះ អាចលុបចោល ឬកម្រិតនូវការអនុញ្ញាតដែលខ្លួនបានផ្ដល់រួចហើយនោះបាន (កថាខណ្ឌទី២ នៃមាត្រា២០)។

ប៉ុន្តែបើគ្រាន់តែជាការផ្លាស់ប្ដូរនូវឆន្ទៈអញ្ញថាភាពរបស់អ្នកមានអំណាចមេបាជាដើម មិនអាចលុបចោល ឬកម្រិតបានទេ។ ពេលណាលុបចោលនូវការអនុញ្ញាតនោះទៅ សមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អនីតិជននោះ នឹងត្រឡប់ទៅស្ថានភាពដើមវិញ។ បញ្ញត្តិនៃមាត្រានេះក៏មិនអាចអនុវត្តដែរ ចំពោះករណីដែលអនីតិជនជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ។ ក្នុងករណីដែលអនីតិជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ច្បាស់ជាមិនមានការអនុញ្ញាតឱ្យមានការប្រកបអាជីវកម្មឡើយ

[21] មាត្រា១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប៉ុន្តែទោះជាមានក៏ដោយ ក៏បញ្ញត្តិស្តីពីអាណាព្យាបាលទូទៅ ត្រូវយកមកអនុវត្តដែរ ហើយសកម្មភាពរបស់អនីតិជនដែលនៅក្រោមអាណាព្យាបាលទូទៅ ទោះបីជាសកម្មភាពនោះស្ថិតក្នុងទំហំនៃការអនុញ្ញាតឱ្យធ្វើអាជីវកម្មក៏ដោយ ក៏អាចលុបចោលសកម្មភាពនោះបានដែរ (មាត្រា២៦)។[22]

លើសពីនេះ ក្រមរដ្ឋប្បវេណីទទួលស្គាល់ថា អនិតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ដូចនេះយើងអាចបកស្រាយបានថា កិច្ចសន្យាដែលធ្វើឡើងដោយអនីតិជនដែលទទួលបានអត្តាធីនភាព មានសុពលភាពដូចកិច្ចសន្យាដែលធ្វើឡើងដោយនីតិជនដែលមានសមត្ថភាពពេញលេញដែរ។[23] អត្តាធីនភាព សំដៅលើស្ថានភាពមួយ ដែលផ្តល់ឱ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនិតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។ លក្ខខណ្ឌដែលអនីតិជនអាចទទួលបានអត្តាធីនភាពមាន ២ស្ថានភាព ដូចខាងក្រោម៖

***ស្ថានភាពទី១៖*** អនីតិជនដែលបានដល់អាយុ ១៦ឆ្នាំ ហើយអាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ និងទទួលបានការប្រកាសទទួលស្គាល់ពីតុលាការតាមពាក្យសុំរបស់អនីតិជននោះ។[24]

***ស្ថានភាពទី២៖*** អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ។ ចំពោះអនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ គឺទទួលបានអត្តាធីនភាពដោយស្វ័យប្រវត្តិ ដោយពុំចាំបាច់មានការប្រកាសទទួលស្គាល់ពីតុលាការនោះទេ។[25]

ជាគោលការណ៍ អនីតិជន ជាជនដែលមិនទាន់ដល់នីតិភាព និងមិនទាន់អាចរៀបអាពាពិពាហ៍បានឡើយ ព្រោះថាអាយុអប្បបរមាដែលសមរម្យសម្រាប់រៀបអាពាហ៍ពិពាហ៍ គឺអាយុ ១៨ឆ្នាំ ដែលជាអាយុដល់នីតិភាព ប៉ុន្តែយោងតាមស្ថានភាពក្នុងសង្គម ជាពិសេសនៅតាមតំបន់ជនបទ យើងឃើញមានអនីតិជនជាច្រើនរៀបអាពាហ៍ពិពាហ៍ ដូចនេះហើយទើបច្បាប់តម្រូវឱ្យមានលក្ខខណ្ឌ ៣ ទើបអនីតិជនអាចរៀបអាពាហ៍ពិពាហ៍បានរួមមាន៖ (១) អនីតិជននោះត្រូវមានអាយុមិនតិចជាង១៦ឆ្នាំ (២) ភាគីម្ខាងទៀតជានីតិជន និង (៣) ទទួលបានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។

ក្នុងករណីខាងលើ ទោះបីជាអនីតិជនដែលបានទទួលអត្តាធីនភាព ដោយអង្គហេតុរៀបអាពាហ៍ពិពាហ៍ បានលែងលះគ្នាក៏ដោយ ក៏អត្តាធីនភាពមិនរលត់ដែរ។[26]

---

[22] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១, កំណត់មាត្រា២០

[23] មាត្រា២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[24] មាត្រា២១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[25] មាត្រា២១ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[26] មាត្រា២១ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

មួយវិញទៀត ពាក់ព័ន្ធនឹងកិច្ចសន្យាការងាររបស់អនីតិជន អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជននោះបានទេ លើកលែងតែអនីតិជននោះផ្តល់សច្ចានុមតិលើកិច្ចសន្យាការងារនោះ។ នៅក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជន អាចធ្វើឱ្យខូចប្រយោជន៍របស់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យាការងារនោះឆ្ពោះទៅអនាគតបាន។[27]

### ខ. ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី និងដែលត្រូវបានតុលាការប្រកាសរបបអាណាព្យាបាលទូទៅតាមពាក្យសុំរបស់អ្នកដែលមានសិទ្ធិដាក់ពាក្យសុំ។[28] អ្នកដែលអាចដាក់ពាក្យសុំឱ្យតុលាការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅមានដូចជា សាមីខ្លួន សហព័ទ្ធរបស់ជននោះ ញាតិដែលស្ថិតនៅក្នុង៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[29] ការដាក់ពាក្យស្នើសុំទៅតុលាការឱ្យប្រកាសរបបអាណាព្យាបាលទូទៅ មិនអាចធ្វើបានឡើយប្រសិនបើសាមីខ្លួនមានអាយុក្រោម ១៥ឆ្នាំ នៅពេលដែលមានពាក្យសុំ។[30] បានន័យថា ប្រសិនបើអនីតិជនដែលមានអាយុមិនទាន់ដល់ ១៥ឆ្នាំ ហើយមានស្ថានភាពដូចជននៅក្រោមអាណាព្យាបាលទូទៅ (មានបញ្ហាខាងផ្នែកបញ្ញាស្មារតី និងខាងផ្លូវចិត្ត) អនីតិជននោះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងថែរក្សា និងត្រួតពិនិត្យរបស់អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ លុះដល់ពេលអនីតិជននោះអាយុ ១៥ឆ្នាំឡើងទៅ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់ជននោះ អាចដាក់ពាក្យសុំទៅតុលាការដើម្បីប្រកាសរបបអាណាព្យាបាលទូទៅចំពោះជនដែលជាអនីតិជននោះ។ ករណីនេះបានន័យថា អនីតិជននោះ ស្ថិតនៅក្រោម អាណាព្យាបាលសម្រាប់អនីតិជនផង និងជាជននៅក្រោមអាណាព្យាបាលទូទៅផង។ ម្យ៉ាងវិញទៀត យើងឃើញថា អ្នកដែលមានសិទ្ធិដាក់ពាក្យសុំឱ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ក្នុងនោះមានហិតូបត្ថម្ភកៈ

[27] មាត្រា២៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[28] មាត្រា២៤ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[29] មាត្រា២៤ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[30] មាត្រា២៤ កថាខណ្ឌ១ វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ផងដែរ។ ស្ថានភាពនេះកើតឡើងចំពោះជនដែលត្រូវបានប្រកាសរបបហិតូបត្ថម្ភរួចហើយ ក្រោយមកវិបត្តិផ្នែកបញ្ញាស្មារតីរបស់ជននោះមានស្ថានភាពកាន់តែធ្ងន់ធ្ងរ ដូចនេះហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ អាចដាក់ពាក្យសុំទៅតុលាការដើម្បីប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ។ ឆ្លើយតបទៅនឹងចំណុចនេះ ដើម្បីជៀសវាងនូវទំនាក់ទំនងគតិយុត្តដ៏ស្មុគស្មាញមួយ ប្រសិនបើជននោះស្ថិតនៅក្រោមរបបហិតូបត្ថម្ភផង និងរបបអាណាព្យាបាលទូទៅផង តុលាការត្រូវប្រកាសលុបចោលការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភចំពោះជននោះ ដូចនេះជននោះក្លាយជាជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅវិញ។[31]

ដោយសារតែជននៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលមានបញ្ហាផ្នែកបញ្ញាស្មារតីធ្ងន់ធ្ងរ ដូចនេះជននៅក្រោមអាណាព្យាបាលទូទៅពុំអាចធ្វើសកម្មភាពដោយឯករាជ្យនោះទេ។ រាល់សកម្មភាពដែលធ្វើឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ព្រោះថាសកម្មភាពនោះធ្វើឡើងដោយជនខ្វះសមត្ថភាព លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃតែប៉ុណ្ណោះ ដែលច្បាប់មិនផ្ដល់សិទ្ធិលុបចោល។[32] សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ គឺជាសកម្មភាពពាក់ព័ន្ធនឹងការរស់នៅរាល់ថ្ងៃ ដូចជាការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃ ការទិញនំចំណីជាដើម។[33] យើងអាចបកស្រាយបានថា បើត្រឹមតែជាសកម្មភាពដែលធ្វើឡើងបម្រើផលប្រយោជន៍ឱ្យការរស់នៅប្រចាំថ្ងៃ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើបាន និងជាកិច្ចសន្យាសុពល ព្រមទាំងពុំអាចធ្វើការលុបចោលបានទេ។ ច្បាប់បញ្ញត្តិបែបនេះ ព្រោះគិតទៅដល់សុវត្ថិភាពនៃកិច្ចការជំនួញរបស់ភាគីម្ខាងទៀត នៃកិច្ចការជួញដូរពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ ម្យ៉ាងទៀតក៏បង្កភាពងាយស្រួលដល់ជននៅក្រោមអាណាព្យាបាលទូទៅក្នុងការទិញរបស់របរប្រើប្រាស់ប្រចាំថ្ងៃដោយខ្លួនឯងបាន។

ខាងក្រោមនេះ ជាឧទាហរណ៍ខ្លះៗដែលធ្វើឡើងដោយភាគីម្ខាងជាជននៅក្រោមអាណាព្យាបាលទូទៅ។

***ឧទាហរណ៍ទី១៖*** «ជ» ត្រូវបានតុលាការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ។ ក្រោយមក គាត់បានទិញអាវមួយដែលមានតម្លៃ ៥ដុល្លារ។ កិច្ចសន្យានេះ មិនអាចលុបចោលបានទេ ព្រោះ

[31] មាត្រា២៨ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[32] មាត្រា២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[33] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១, កំណត់មាត្រា២៦

ជាអញ្ញត្រកម្មនៃច្បាប់ ដោយលើកលែងករណីដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ជាកិច្ចសន្យាសុពល។

***ឧទាហរណ៍ទី២៖*** «ណ» ជាជននៅក្រោមអាណាព្យាបាលទូទៅ។ គាត់បានចុះកិច្ចសន្យាប្រទានកម្មលុយ ១០០ដុល្លារ ឱ្យទៅ «ង» ដែលជាអ្នកជិតខាង។ កិច្ចសន្យានេះ អាចលុបចោលបាន ព្រោះធ្វើឡើងដោយជនខ្វះសមត្ថភាព។

នៅពេលដែលសមត្ថភាពខាងឆន្ទៈក៏ដូចជាការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនមានភាពល្អប្រសើរឡើងវិញ នោះតុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុងបួនថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។ [34] ក្រោយការប្រកាសលុបចោលរបបអាណាព្យាបាលទូទៅ ជននោះត្រូវបានក្លាយជាជនមានសមត្ថភាពឡើងវិញ និងអាចធ្វើកិច្ចសន្យាសុពលដូចជនមានសមត្ថភាពដែរ។

### គ. ជនស្ថិតនៅក្រោមហិតូបត្ថម្ភ

ជនស្ថិតនៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី និងដែលត្រូវបានតុលាការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់អ្នកដែលមានសិទ្ធិដាក់ពាក្យសុំ។ អ្នកដែលមានសិទ្ធិដាក់ពាក្យសុំទៅតុលាការឱ្យប្រកាសការចាប់ផ្តើមហិតូបត្ថម្ភមានដូចជា សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង៤ថ្នាក់ អ្នកអាណាព្យបាល អ្នកត្រួតពិនិត្យអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។ ចំពោះការដាក់ពាក្យសុំប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ក៏មានការកំណត់អាយុរបស់សាមីខ្លួនដូចការដាក់ពាក្យសុំប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅដែរ ពោលគឺសាមីខ្លួនត្រូវមានអាយុយ៉ាងតិច ១៥ឆ្នាំ នៅពេលដែលមានពាក្យសុំ។

ជាគោលការណ៍ សកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភធ្វើ ត្រូវតែមានការយល់ព្រមពីហិតូបត្ថម្ភកៈ លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃប៉ុណ្ណោះ។ ក្រមរដ្ឋប្បវេណីក៏មានចែងអំពីសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភធ្វើ ដោយពុំមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយអាចលុបចោលបាន មានដូចខាងក្រោម៖[35]

---

[34] មាត្រា២៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[35] មាត្រា៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- ការទទួល ឬការប្រើប្រាស់ប្រាក់ទុន (ឧទាហរណ៍ដូចជា៖ ការដកប្រាក់ពីគណនីបញ្ញើ ការទទួលនូវសំណងនៃបំណុល ការឱ្យគេខ្ចីប្រាក់)
- ការខ្ចីទ្រព្យ ឬការធានា
- ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត
- ការធ្វើសកម្មភាពបណ្ដឹង
- ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តិកម្ម
- ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការបែងចែកនូវមរតក
- ការប្រកែកមិនទទួលប្រទានកម្ម ឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក
- ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំៗ
- ការធ្វើភតិសន្យាដែលមានអំឡុងពេលលើសពី៣ឆ្នាំចំពោះដីធ្លី លើសពី២ឆ្នាំចំពោះអាគារ លើសពី៦ខែចំពោះចលនវត្ថុ
- សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលមានសិទ្ធិដាក់ពាក្យសុំទៅតុលាការដើម្បីប្រកាសការចាប់ផ្ដើមរបបហិតូបត្ថម្ភ ឬហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យ ហិតូបត្ថម្ភកៈ។

គួរបញ្ជាក់ផងដែរថា ហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ដោយហេតុថា សិទ្ធិអំណាចរបស់ហិតូបត្ថម្ភកៈ គឺជាការផ្ដល់នូវការយល់ព្រមចំពោះសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើឡើងដោយឯករាជ្យបាន មិនមែនជាការផ្ដល់សិទ្ធិអំណាចឱ្យធ្វើជាអ្នកតំណាងសាមីខ្លួន ដូចអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលទេ។

ដូចបានរៀបរាប់ខាងលើរួចហើយថា ក្រមរដ្ឋប្បវេណីចាត់ទុកជននៅក្រោមហិតូបត្ថម្ភ ជាជនមួយប្រភេទដែលត្រូវបានកម្រិតសមត្ថភាព ដោយយកមូលហេតុនៃការកង្វះនូវសមត្ថភាពខាងឆន្ទៈ និងមានបញ្ហាផ្នែកបញ្ញាស្មារតី ដូចនេះនៅពេលដែលស្ថានភាពនៃការយល់ដឹងទាក់ទងនឹងផ្នែកស្មារតីរបស់ជននៅក្រោមហិតូបត្ថម្ភមានភាពល្អប្រសើរឡើងវិញ នោះក៏ពុំមានភាពចាំបាច់អីដែលត្រូវបន្តទុកជននោះឱ្យស្ថិតនៅក្រោមរបបហិតូបត្ថម្ភតទៅទៀតដែរ ក្នុងករណីនេះតុលាការត្រូវលុបចោលនូវការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ

អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[36] នៅពេលដែលតុលាការប្រកាសលុបចោលការចាប់ផ្ដើមហិតូបត្ថម្ភ បានន័យថា ជននៅក្រោមហិតូបត្ថម្ភ បានរួចផុតពីការនៅក្រោមរបបហិតូបត្ថម្ភ ហើយលែងជាជនត្រូវបានកម្រិតសមត្ថភាពទៀតហើយ ព្រមទាំងអាចធ្វើកិច្ចសន្យាសុពលដូចជនមានសមត្ថភាពដែរ។

### ១.៣ អ្នកដែលមានសិទ្ធិលុបចោល និងផ្ដល់សច្ចានុមតិ

ចំពោះកិច្ចសន្យាដែលអាចលុបចោលបាន មិនមែននរណាក៏អាចប្រកាសលុបចោលកិច្ចសន្យាបាននោះទេ ព្រោះកិច្ចសន្យាដែលមានមូលហេតុអាចលុបចោល គ្មានអានុភាពប៉ះពាល់ដល់សង្គមទាំងមូលទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងច្បាស់ពីអ្នកដែលមានសិទ្ធិលុបចោលទៅតាមមូលហេតុដែលនាំឱ្យកិច្ចសន្យាអាចលុបចោលបាន។ រីឯអ្នកដែលមានសិទ្ធិផ្ដល់សច្ចានុមតិក៏ត្រូវបានកំណត់ច្បាស់ដូចគ្នាផងដែរ។

#### ១.៣.១ អ្នកដែលមានសិទ្ធិលុបចោល

##### ១.៣.១.១ អ្នកមានសិទ្ធិលុបចោលចំពោះកិច្ចសន្យាដែលមានវិការៈ

អ្នកដែលមានសិទ្ធិលុបចោលសកម្មភាពដែលអាចលុបចោលបាន ដោយយោងលើមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈដូចមានចែងចាប់ពីមាត្រា៣៤៦ ដល់មាត្រា៣៥១ មានដូចជា៖

- អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះប្រសិនបើមាន ឬ
- សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ
- អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកបង្ហាញឆន្ទៈ
- អច្ច័យលាភីសកលពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ (មាត្រា១២១២)។

អ្នកតំណាងដែលច្បាប់បានកំណត់សំដៅទៅលើអ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅប៉ុណ្ណោះ។ ចំពោះហិតូបត្ថម្ភកៈវិញ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ព្រោះហិតូបត្ថម្ភកៈមានតួនាទីគ្រាន់តែផ្ដល់ការយល់ព្រមទៅលើសកម្មភាពរបស់អ្នកនៅក្រោមហិតូបត្ថម្ភប៉ុណ្ណោះ។[37]

[36] មាត្រា៣១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[37] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១, កំណត់មាត្រា៣០

ជាការគួរឱ្យកត់សម្គាល់មួយទៀត គឺ នៅក្នុងមាត្រា៣៥៩ មិនបានចែងពីអច្ច័យលាភីសកល ពីអ្នកដែលបង្ហាញឆន្ទៈមានវិការៈទេ តែបើគេក្រលេកមើលពីគោលគំនិតនៃមាត្រា១២១២ អច្ច័យលាភីសកល ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។[38]

***ឧទាហរណ៍៖*** «ក» បានធ្វើកិច្ចសន្យាខ្ចីប្រើ ជាមួយ «ខ» ហើយបានឱ្យរថយន្តរបស់ខ្លួនទៅ «ក» ខ្ចី ដោយសារការឆបោករបស់ «ខ» ក្រោយមក «ក» បានទទួលមរណភាព។ បើ «ក» បានធ្វើអច្ច័យទានសកលទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅ «ង» នោះ «ង» ក៏អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាខ្ចីប្រើ ដោយយោងលើការឆបោកនោះបានដែរ។

***ឧទាហរណ៍៖*** «ក» បានបង្ហាញឆន្ទៈធ្វើកិច្ចសន្យាខ្ចីប្រើ ជាមួយ «ខ» ដោយសារ «ខ» បានគម្រាមកំហែង «ក»។ ករណីបែបនេះ «ក» អាចលុបចោលកិច្ចសន្យានេះបាន។ ម្យ៉ាងទៀតបើ «ក» ជាអនីតិជន ហើយ «គ» ជាអ្នកមានអំណាចមេបាលើ «ក» នោះ «គ» អាចលុបចោលកិច្ចសន្យាដោយយោងលើមូលហេតុនៃការឆបោកបាន។

ម្យ៉ាងវិញទៀតផងដែរ ប្រសិនបើ «ក» បានទទួលមរណភាព ហើយ មាន «ច» ជាសន្តតិជនតែម្នាក់ នោះ «ច» អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានោះបាន។ ករណីមួយទៀត ប្រសិនបើ «ក» បានធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាដូចមានចែងក្នុងមាត្រា៥១២ ឱ្យទៅ «ជ» នោះ «ជ» ក៏អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានោះបានដែរ។

### ១.៣.១.២ អ្នកមានសិទ្ធិលុបចោលចំពោះកិច្ចសន្យាធ្វើឡើងដោយជនខ្វះសមត្ថភាព

ពាក្យសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ដែលមានចែងក្នុងមាត្រា៣៥៩ កថាខណ្ឌទី២ គឺមានន័យដូចគ្នានឹងពាក្យ សមត្ថភាពខាងឆន្ទៈ ដែលមានចែងនៅក្នុងមាត្រា១៤ ដែរ។[39] អ្នកដែលមានសិទ្ធិលុបចោលចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយយោងលើមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬការកម្រិតសមត្ថភាពក្នុងការបង្ហាញឆន្ទៈមានដូចជា៖

- អ្នកបង្ហាញឆន្ទៈ
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកបង្ហាញឆន្ទៈ
- ហិតូបត្ថម្ភកៈរបស់អ្នកបង្ហាញឆន្ទៈ
- សន្តតិជននៃអ្នកបង្ហាញឆន្ទៈ
- អច្ច័យលាភីសកលរបស់អ្នកបង្ហាញឆន្ទៈ

[38] មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៧, ២០១៦
[39] មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៧, ២០១៦

- អ្នកដែលទទួលបន្តបានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ (មាត្រា៥១៤ នៃក្រម រដ្ឋប្បវេណី)។

ជាការកត់សម្គាល់ មាត្រា៣៥៩ មិនបានបញ្ញត្តិពីអ្នកទទួលបន្តបានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈទេ តែបើក្រលេកមើលគោលគំនិតមាត្រា៥១៤ វិញ អ្នកដែលទទួលបន្តបានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។[40]

ម្យ៉ាងវិញទៀតក៏មានការកំណត់ពិសេសចំពោះអ្នកដែលត្រូវបានកម្រិតសមត្ថភាព ដោយត្រូវបានផ្តល់សិទ្ធិឱ្យលុបចោលសកម្មភាពដែលអាចលុបចោលបានដោយសេរី ប៉ុន្តែក្រោយពីបានអនុវត្តសិទ្ធិលុបចោលហើយ ជននោះមិនអាចលុបចោលការអនុវត្តសិទ្ធិលុបចោលនោះវិញបានឡើយ។[41]

***ឧទាហរណ៍៖*** «ក» ជាអនីតិជន បានធ្វើកិច្ចសន្យាជួលរថយន្តជាមួយ «ខ»។ «ក» បានដឹងថាខ្លួនអាចលុបចោលកិច្ចសន្យានោះបាន ព្រោះខ្លួនជាជនត្រូវបានកម្រិតសម្ថភាពក៏សម្រេចចិត្តលុបចោលកិច្ចសន្យានោះចោល។ ករណីនេះ បើ «ក» ចង់លុបចោល ការលុបចោលកិច្ចសន្យានោះវិញ គឺមិនអាចធ្វើបានទេ។

***ជាឧទាហរណ៍មួយទៀត៖*** «ក» ជាអនីតិជន បានធ្វើកិច្ចសន្យាទិញទូរស័ព្ទស្មាតហ្វូនក្នុងតម្លៃ ១ ០០០ដុល្លាអាមេរិក ពីហាងលក់ទូរស័ព្ទមួយកន្លែង។ «ខ» ជាអ្នកអាណាព្យាបាលដែលត្រូវបានតុលាការចាត់តាំងរបស់ «ក» នោះ «ខ» អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាទិញទូរស័ព្ទរវាង «ក» និងហាងលក់ទូរស័ព្ទបាន។

ម្យ៉ាងវិញទៀត បើ «ក» ជាជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភដូចមានចែងនៅក្នុងមាត្រា២៨ ហើយបានធ្វើកិច្ចសន្យាខ្ចីបរិភោគនូវប្រាក់ចំនួន ២ ០០០ដុល្លាអាមេរិក ជាមួយ «ខ» នោះ ហិតូបត្ថម្ភកៈ ដែលចាត់តាំងដោយតុលាការមានសិទ្ធិលុបចោលសកម្មភាពនោះវិញបាន។

***ចំពោះករណីសិក្សាមួយទៀត៖*** «ក» បានធ្វើកិច្ចសន្យាលក់ទិញគំនូរដែលមានតម្លៃ ៥០០០ ដុល្លារអាមេរិក ដោយពេលធ្វើកិច្ចសន្យានោះ គឺ «ក» ស្ថិតក្នុងសភាពស្រវឹងខ្លាំង បន្ទាប់មក «ក» បានជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប់នៅយប់ដដែល។ «ខ» ដែលជាសន្តតិជនរបស់ «ក» អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាលក់ទិញគំនូរនោះបាន។ ម្យ៉ាងវិញទៀត បើពេលនៅរស់ «ក» បានធ្វើអច្ច័ទានសកលឱ្យទៅ «ង» នោះ «ង» ក៏អាចលុបចោលកិច្ចសន្យានោះបានដូចគ្នា។

[40] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៨, ២០១៦
[41] ដដែល

### ១.៣.២ អ្នកដែលមានសិទ្ធិផ្តល់សច្ចានុមតិ

សច្ចានុមតិអាចត្រូវបានផ្តល់ដោយអ្នកមានសិទ្ធិលុបចោល។ [42] ចំពោះករណីដែលសកម្មភាពដែលអាចលុបចោលបានដោយយោងលើមូលហេតុការបង្ហាញឆន្ទៈមានវិការៈ អ្នកដែលមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងពីមូលហេតុនៃការលុបចោល។ [43] ចំណែកឯសកម្មភាពដែលអាចលុបចោលបាន ដោយយោងលើមូលហេតុ ជនដែលបានបង្ហាញឆន្ទៈជាជនដែលត្រូវបានកម្រិតសមត្ថភាពវិញនោះ សាមីខ្លួនអាចផ្តល់សច្ចានុមតិបានតែនៅក្រោយពេលដែលស្ថានភាពដែលត្រូវបានកម្រិតសមត្ថភាពនោះ រលត់ប៉ុណ្ណោះ។ នេះគឺមានភាពខុសគ្នាពីការលុបចោលដែលអនុញ្ញាតឱ្យជនដែលត្រូវបានកម្រិតសមត្ថភាពលុបចោលសកម្មភាពបាន ទោះបីមុនពេលការកម្រិតសមត្ថភាពនោះរលត់ក៏ដោយ។[44] យ៉ាងណាមិញ ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ) និងហិតូបត្ថម្ភកៈ អាចផ្តល់សច្ចានុមតិបានទាំងមុនពេលដែលជននោះត្រូវបានរួចផុតពីការកម្រិតសមត្ថភាព និងក្រោយពេលដែលការកម្រិតសមត្ថភាពនោះត្រូវបានរលត់។[45]

ចំណុចគួរពិចារណាមួយគឺ ប្រសិនបើអ្នកដែលត្រូវបានកម្រិតសមត្ថភាព បានទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ តើគេអាចផ្តល់សច្ចានុមតិបានដែរ ឬយ៉ាងណានោះ នៅក្នុងក្រមមិនបានធ្វើការបញ្ជាក់ឱ្យច្បាស់ទេ។ យ៉ាងណាមិញ បើយោងទៅលើការបកស្រាយមាត្រា១៨ (សិទ្ធិលុបចោលសកម្មភាពរបស់អនីតិជន) មាត្រា២៦ (សិទ្ធិលុបចោលសកម្មភាពរបស់ជននៅក្រោមរបបអាណាព្យាបាលទូទៅ) និងមាត្រា៣០ (សិទ្ធិលុបចោលសកម្មភាពរបស់ជននៅក្រោមរបបហិតូបត្ថម្ភកៈ) អាចត្រូវបានបកស្រាយថា អនីតិជន និងជននៅក្រោមរបបហិតូបត្ថម្ភកៈ បើបានទទួលការយល់ព្រម គឺអាចធ្វើសច្ចានុមតិបាន ចំណែកឯជននៅក្រោមរបបអាណាព្យាបាលទូទៅ ទោះបីជាបានទទួលការយល់ព្រម ឬអត់ ក៏មិនអាចធ្វើសច្ចានុមតិបានដែរ។[46]

## ១.៤ វិធីលុបចោលកិច្ចសន្យា និងការផ្តល់សច្ចានុមតិ

### ១.៤.១ វិធីនៃការលុបចោលកិច្ចសន្យា

ការលុបចោលកិច្ចសន្យាដែលអាចលុបចោលបាន គឺត្រូវធ្វើឡើងតាមរយៈការជូនដំណឹងទៅ

[42] មាត្រា៣៦១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា២០០៧

[43] ដដែល

[44] ដដែល

[45] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, កំណត់មាត្រា៣៦១

[46] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ១០, ២០១៦

ភាគីម្ខាងទៀតនៃកិច្ចសន្យា។ ការជូនដំណឹងមានអានុភាពនៅពេលដែលការជូនដំណឹងនោះបានទៅដល់ភាគីម្ខាងទៀតនៃកិច្ចសន្យា។[47] ការជូនដំណឹងពីការលុបចោល មិនចាំបាច់ត្រូវធ្វើឡើងតាមប្រព័ន្ធតុលាការទេ។ [48] គេអាចធ្វើឡើងតាមរយៈការផ្ញើរសំបុត្រ ឬទៅប្រាប់ដោយផ្ទាល់។ មកដល់បច្ចុប្បន្ននេះ មធ្យោបាយជូនដំណឹងកាន់តែសម្បូរបែប ព្រោះមានទូរស័ព្ទ កុំព្យូទ័រ និងមានអ៊ីនធឺណេតដែលអាចឱ្យគេធ្វើការជូនដំណឹងតាមសារអេឡិចត្រូនិច ឬទាក់ទងតាមទូរស័ព្ទបានយ៉ាងងាយស្រួល ដោយធ្វើតាមមធ្យោបាយណាក៏ដោយឱ្យតែការជូនដំណឹងនោះបានដល់ភាគីម្ខាងទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីជៀសវាងពេលមានវិវាទ ភាគីអាចប្រើមធ្យោបាយណាដែលអាចរក្សាទុកភស្តុតាងបានពីការជូនដំណឹងតាមរយៈលិខិត ដោយមានចុះហត្ថលេខា ឬស្នាមមេដៃរបស់ភាគីទាំងសងខាង ឬតាមរយៈសារអេឡិចត្រូនិច។ល។

### ១.៤.២ វិធីនៃការផ្តល់សច្ចានុមតិ

សច្ចានុមតិ គឺជាសកម្មភាពដែលបុគ្គលដែលមានសិទ្ធិលុបចោល បានបង្ហាញជាស្ពាពរថាខ្លួនមិនអនុវត្តសិទ្ធិលុបចោលដោយផ្អែកលើបុរេលក្ខខណ្ឌដែលបានដឹងថា សកម្មភាពរបស់ខ្លួនអាចលុបចោលបាន។[49]

វិធីធ្វើសច្ចានុមតិ ក៏ដូចគ្នាទៅនឹងវិធីលុបចោលដែរ គឺអ្នកដែលមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិទៅលើកិច្ចសន្យាបានតាមរយៈការជូនដំណឹងទៅភាគីម្ខាងទៀតនៃកិច្ចសន្យា។ ការផ្តល់សច្ចានុមតិ នឹងមានអានុភាពបាននៅពេលដែលការជូនដំណឹងបានទៅដល់ភាគីម្ខាងទៀត នៃកិច្ចសន្យាប៉ុណ្ណោះ និងមិនចាំបាច់ធ្វើតាមរយៈតុលាការទេ។[50] ហើយវិធីនៃការជូនដំណឹង អាចធ្វើឡើងតាមរយៈលិខិត ឬផ្ញើរសារអេឡិចត្រូនិច ឬប្រាប់ដោយផ្ទាល់ ឬតាមទូរស័ព្ទ ។ល។

លើសពីនេះ ក្នុងករណីដែលអ្នកអាចផ្តល់សច្ចានុមតិ បានធ្វើនូវសកម្មភាពមួយចំនួនដែលបង្ហាញថាគាត់ទទួលស្គាល់នូវកិច្ចសន្យានោះ ច្បាប់ចាត់ទុកថាជា សច្ចានុមតិដែលច្បាប់កំណត់។ សច្ចានុមតិដែលច្បាប់កំណត់មាន ៩ករណី ដូចខាងក្រោម៖

- ការអនុវត្តកាតព្វកិច្ចទាំងមូល ឬមួយផ្នែកចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ កាដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ។

[47] មាត្រា៣៦០ នៃក្រមរដ្ឋប្បវេណីកម្ពុជា២០០៧

[48] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៥, ២០១៦

[49] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, កំណត់មាត្រា៣៦១

[50] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៥, ២០១៦

***ឧទាហរណ៍៖*** «ក» បានព្រមព្រៀងទិញគំនូរពី «ខ» ដោយភាន់ច្រលំថា គំនូរនោះគូរឡើងដោយវិចិត្រករ A។ «ក» និង «ខ» បានព្រមព្រៀងថា នឹងបង់ប្រាក់ក្នុងរយៈពេលមួយសប្ដាហ៍បន្ទាប់ពីបានទទួលគំនូរ។ បន្ទាប់មក «ក» បានដឹងថាខ្លួនមានការភាន់ច្រលំទៅលើម្ចាស់ស្នាដៃគំនូរនោះ តែ «ក» នៅតែព្រមបង់ប្រាក់ថ្លៃគំនូរឱ្យទៅ «ខ»។ ករណីនេះ «ក» មិនអាចលុបចោលកិច្ចសន្យាវិញបានទេ ព្រោះខ្លួនបានអនុវត្តកាតព្វកិច្ចរួចហើយ ទោះបីជាដឹងថាមានការឆបោកក៏ដោយ ព្រោះច្បាប់កំណត់ថាជាការផ្ដល់សច្ចានុមតិ។

- ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬការទាមទារឱ្យភាគីម្ខាងទៀតអនុវត្ត។

***ឧទាហរណ៍៖*** «ក» និង «ខ» បានបង្កើតកិច្ចសន្យាទិញលក់ ម៉ាស៊ីនបោកសម្លៀកបំពាក់មួយគ្រឿង ដោយ «ខ» បានប្រាប់ថាជាផលិតផលមកពីជប៉ុន។ ភាគីទាំងពីរព្រមព្រៀងគ្នាឱ្យ «ខ» ដឹកជញ្ជូនម៉ាស៊ីននោះទៅផ្ទះរបស់ «ក»។ មុនពេល «ខ» ដឹកជញ្ជូនម៉ាស៊ីននោះ មកឱ្យ«ក» ភាគី «ក» បានដឹងថាម៉ាស៊ីននោះមិនមែនជាផលិតផលមកពីជប៉ុនទេ តែ «ក» នៅតែទាមទារឱ្យ «ខ» ដឹកម៉ាស៊ីននោះមកតាមការព្រមព្រៀង។ ករណីនេះ ក៏ជាការផ្ដល់សច្ចានុមតិតាមច្បាប់កំណត់ដែរ ដូច្នេះ «ក» មិនអាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាវិញបានទេ។

- អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀត នូវសិទ្ធិទាំងមូលឬមួយផ្នែកចំពោះសិទ្ធិ ដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន។

***ឧទាហរណ៍៖*** «ក» និង «ខ» បានព្រមព្រៀងទិញលក់វត្ថុបុរាណមួយក្នុងតម្លៃ ១០០ ០០០ ដុល្លារ ដោយ «ខ» បានប្រាប់ថា វត្ថុនោះមានអាយុកាល ១ ០០០ឆ្នាំមកហើយ តែការពិត វត្ថុនោះមានអាយុកាលត្រឹមតែ ១០០ឆ្នាំប៉ុណ្ណោះ។ ក្រោយមក «ក» បានដឹងពីការពិត តែមិនបានអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានោះវិញទេ ហើយបានធ្វើការលក់វត្ថុបុរាណនោះឱ្យទៅតតិយជនម្នាក់ទៀត។ ដោយសារ «ក» បានចាត់ចែងវត្ថុនោះទាំងដែលបានដឹងថាខ្លួនអាចលុបចោលកិច្ចសន្យាបាន គឺជាការផ្ដល់សច្ចានុមតិដែលកំណត់ដោយច្បាប់ ហេតុដូច្នេះ «ក» មិនអាចអនុវត្តសិទ្ធិលុបចោលបានទៀតទេ។

ទោះបីជាយ៉ាងណាក៏ដោយ សច្ចានុមតិដែលកំណត់ដោយច្បាប់ នឹងមិនកើតឡើងឡើយ ប្រសិនបើអ្នកបង្ហាញឆន្ទៈ មានបបនីយថា ខ្លួនមិនបានផ្ដល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះកើតឡើង។[51] ពាក្យថា «បបនីយថាខ្លួនមិនបានផ្ដល់

[51] មាត្រា៣៦២ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សច្ចានុមតិ» មានន័យថា បុគ្គលដែលបានធ្វើសកម្មភាពត្រូវបង្ហាញចេញមកក្រៅថាខ្លួនមិនបានផ្តល់សច្ចានុមតិទេ ទោះតាមការសរសេរ ឬតាមការនិយាយក្តី។[52]

**ឧទាហរណ៍៖** «ក» ជាអនីតិជន បានបង្កើតកិច្ចសន្យាទិញលក់ដីចម្ការស្វាយមួយកន្លែង។ «គ» ដែលជាអ្នកមានអំណាចមេបាបានប្រគល់ប្រាក់ថ្លៃទិញលក់នោះឱ្យទៅម្ចាស់ចម្ការ ដោយសារដីនោះនឹងត្រូវរឹបអូសដោយម្ចាស់បំណុល បើម្ចាស់ចម្ការមិនព្រមសងបំណុល។ ពេលប្រគល់ប្រាក់នោះ «គ» បានបញ្ជាក់ច្បាស់ជាមួយម្ចាស់ចម្ការថា នេះមិនមែនជាការផ្តល់សច្ចានុមតិលើសកម្មភាពទិញលក់របស់ «ក» ទេ។ ដូច្នេះ វាមិនមែនជាសច្ចានុមតិដែលច្បាប់កំណត់ទេ។

## ១.៥ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

អាជ្ញាយុកាល គឺជាអំឡុងពេលមួយដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬការរលត់សិទ្ធិណាមួយ។[53] ដូចនេះ អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល មានន័យថា ជាអំឡុងពេលមួយដែលសិទ្ធិលុបចោលកិច្ចសន្យារបស់អ្នកមានសិទ្ធិលុបចោលត្រូវរលត់ដោយសារហួសអំឡុងពេលដែលច្បាប់បានកំណត់។ ការទទួលស្គាល់សិទ្ធិក្នុងការលុបចោលកិច្ចសន្យា ទោះបីមូលហេតុវិការៈនៃការបង្ហាញឆន្ទៈក្តី ដោយមូលហេតុអសមត្ថភាពក្តី គឺក្នុងគោលដៅការពារផលប្រយោជន៍របស់អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ និងជនត្រូវបានកម្រិតសមត្ថភាពផងដែរនោះ ផលប្រយោជន៍របស់ភាគីម្ខាងទៀត ក៏ត្រូវបានយកមកពិចារណាផងដែរ។ យើងឃើញថា ច្បាប់កំណត់អំពីអំឡុងពេលដែលអ្នកមានសិទ្ធិលុបចោលនៅមានសិទ្ធិក្នុងការលុបចោលកិច្ចសន្យា ក៏ដូចជាសិទ្ធិក្នុងការទាមទារឱ្យសងតាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយហេតុបែបនេះ គឺដោយសារផលប៉ះពាល់ដោយមូលហេតុនៃការលុបចោលកិច្ចសន្យា គឺត្រឹមលក្ខណៈឯកជនប៉ុណ្ណោះ ហើយហេតុទាំងអស់នោះអាចកើតឡើងជារឿយៗក្នុងពាណិជ្ជកម្ម និងក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដូចនេះបើច្បាប់មិនកំណត់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោលនោះទេ ពិតជាមានភាពមិនស្រួលចិត្តក្នុងការបង្កើតកិច្ចសន្យា រួមទាំងក្រោយពេលបង្កើតកិច្ចសន្យាផងដែរ តួយ៉ាងប្រសិនបើយើងទទួលស្គាល់សិទ្ធិលុបចោលរបស់អ្នកលុបចោលដោយគ្មានកំណត់ពេល នោះនឹងនាំឱ្យមានអស្ថេរភាពផ្នែកកិច្ចការជំនួញរបស់ភាគីម្ខាងទៀតនៃការលុបចោលជាមិនខាន ដោយហេតុថាមិនដឹងជាកិច្ចសន្យាអាចនឹងត្រូវបានលុបចោលនៅពេលណានោះទេ។ អាស្រ័យហេតុនេះ ដើម្បី

[52] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ១៥, ២០១៦
[53] សន្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចំណុចទី១៩៦

ធានានូវតុល្យភាពរវាងភាគីទាំងសងខាងនៃកិច្ចសន្យា ទើបច្បាប់បានកំណត់នូវរយៈពេលច្បាស់លាស់សម្រាប់អ្នកមានសិទ្ធិលុបចោលក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល ត្រូវបានបែងចែកចេញជាពីរករណីដូចខាងក្រោម៖

***ករណីទី១៖*** ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេលបីឆ្នាំ គិតចាប់តាំងពីពេលដែលខ្លួនក្លាយជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និងសិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើងដោយសារការលុបចោលនោះត្រូវរលត់។[54]

រយៈពេលដែលអាចផ្តល់សច្ចានុមតិបាន មានលក្ខណៈខុសគ្នារវាងអ្នកបង្ហាញឆន្ទៈដោយមានវិការៈ និងអសមត្ថជន។ ចំពោះអ្នកបង្ហាញឆន្ទៈដោយមានវិការៈ អាចសម្រេចចិត្តអំពីការផ្តល់សច្ចានុមតិចាប់តាំងពីពេលដែលបានដឹងអំពីវិការៈនៃការបង្ហាញឆន្ទៈ ហើយអាជ្ញាយុកាលចាប់ផ្តើមរាប់ពីពេលនោះឯង។ ចំណែកឯករណីអសមត្ថជន ពួកគេអាចធ្វើការផ្តល់សច្ចានុមតិ នៅពេលដែលពួកគេក្លាយជាជនមានសមត្ថភាព ហើយអាជ្ញាយុកាលចាប់ផ្តើមគណនាពីពេលនោះតទៅ។ ទន្ទឹមនឹងនេះ ចំពោះអ្នកអាណាព្យាបាលនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាជ្ញាយុកាលត្រូវចាប់ផ្តើមរាប់ពីពេលដែលអាណាព្យាបាលបានដឹងអំពីមូលហេតុនៃការលុបចោល។

***ករណីទី២៖*** ប្រសិនបើហួសអំឡុងពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពនោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ។

នៅពេលដែលអ្នកមានសិទ្ធិលុបចោលបានដឹងអំពីមូលហេតុ នៃការលុបចោលក្រោយពេល ១០ឆ្នាំនៃការបង្កើតកិច្ចសន្យា នោះយើងមិនគួរទទួលស្គាល់នូវសិទ្ធិលុបចោលនោះទៀតឡើយ ព្រោះថានេះជាអំឡុងពេលដ៏យូរមួយ ហើយម្យ៉ាងវិញទៀត កម្មវត្ថុនៃកិច្ចសន្យាអាចនឹងត្រូវបានចាត់ចែងបន្តប៉ុន្មានដងរួចទៀតក៏ថាបាន ដូចនេះបើនៅតែទទួលស្គាល់នូវសិទ្ធិលុបចោលនៅរយៈពេលហួសពី ១០ឆ្នាំ ចាប់តាំងពីកិច្ចសន្យាត្រូវបានបង្កើត នឹងធ្វើឱ្យមានស្ថានភាពស្មុគស្មាញមិនខាន។ ហេតុដូចនេះហើយ ទើបច្បាប់កំណត់ថា ប្រសិនបើអ្នកមានសិទ្ធិលុបចោលបានដឹងអំពីមូលហេតុនៃការលុបចោលក្នុងអំឡុងពេលហួសពី១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃកិច្ចសន្យាត្រូវបានបង្កើត នោះសិទ្ធិលុបចោលកិច្ចសន្យានឹងត្រូវរលត់។

យើងឃើញថា នៅក្នុងករណីទី១ បានកំណត់ថា សិទ្ធិលុបចោល និងសិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុ ត្រូវរលត់ក្នុងអំឡុងពេល៣ឆ្នាំ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិ ចំណែកឯក្នុងករណីទី២វិញ បានកំណត់ត្រឹមតែសិទ្ធិលុបចោលប៉ុណ្ណោះដែលត្រូវរលត់ ប្រសិនបើ

[54] មាត្រា៣៦៣ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ហួសរយៈពេល១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព ដោយពុំមានកំណត់អំពីសិទ្ធិទាមទារឱ្យសងតាមសេចក្តីច្រើនដោយឥតហេតុទេ។ ដូចនេះ ចំពោះករណីទី២ យើងមិនអាចយកសិទ្ធិទាមទារឱ្យសងតាមសេចក្តីចម្រើនដោយឥតហេតុមកអនុវត្តទេ បានន័យថា សិទ្ធិនេះត្រូវរលត់ក្នុងអំឡុងពេល៣ឆ្នាំ (ករណីទី១)។

## ១.៦ អានុភាពនៃការលុបចោល

អានុភាព គឺជាផលគតិយុត្ត ដែលកើតចេញពីលិខិតគតិយុត្ត ដូចជា កិច្ចសន្យា ច្បាប់ សេចក្តីសម្រេចរបស់តុលាការ សេចក្តីសម្រេចរបស់រដ្ឋបាល។ល។[55] យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សកម្មភាព (កិច្ចសន្យា ឬសកម្មភាពឯកតោភាគី) ដែលអាចលុបចោលបានមានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។[56] ត្រង់ចំណុចនេះ មានន័យថា កិច្ចសន្យានោះមានមូលហេតុនៃការលុបចោល ដែលអាចជាការបង្ហាញឆន្ទៈដោយមានវិការៈ ឬមូលហេតុកង្វះសមត្ថភាពរបស់ភាគី ប៉ុន្តែពុំទាន់ត្រូវបានលុបចោល ដូចនេះកិច្ចសន្យានោះមានអានុភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលកិច្ចសន្យានោះ ដែលយើងអាចហៅថា សុពលភាពមិនពេញលេញ។ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោលបានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ។[57] ប្រសិនបើអ្នកមានសិទ្ធិលុបចោល ឬអ្នកដែលមានសិទ្ធិផ្តល់សច្ចានុមតិបានផ្តល់សច្ចានុមតិស្របតាមលក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ ចំពោះកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល នោះបានសេចក្តីថា សុពលភាពមិនពេញលេញបានក្លាយទៅជាសុពលភាពស្ថាពរ។ ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោល សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង [58] ឬអាចនិយាយម្យ៉ាងទៀតថា ការលុបចោលកិច្ចសន្យាមានអានុភាពប្រតិសកម្ម។ អានុភាពប្រតិសកម្ម គឺជាអានុភាពនៃលក្ខខណ្ឌគតិយុត្ត ដែលមានទៅលើសកម្មភាពពីអតីតកាល ឬអាចហៅថាអានុភាពធាក់ថយក្រោយ។ ប្រសិនបើអ្នកមានសិទ្ធិលុបចោលបានសម្រេចចិត្តលុបចោលកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល អាចសន្មតបានថា អ្នកមានសិទ្ធិលុបចោលមិនចង់ឱ្យកិច្ចសន្យានោះមានអានុភាពមកលើខ្លួនតាំងពីដំបូងមកម្ល៉េះ។ សរុបមក

---

[55] សន្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចំណុច២០០

[56] មាត្រា៣៥៨ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[57] មាត្រា៣៥៨ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[58] មាត្រា៣៥៨ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អានុភាពនៃការលុបចោលកិច្ចសន្យា គឺធ្វើឱ្យកិច្ចសន្យានោះបាត់បង់អានុភាព និងមានន័យស្មើគ្មានការបង្កើតកិច្ចសន្យាតាំងពីដំបូងម្ល៉េះ។

បន្ទាប់ពីសិក្សាអំពីការលុបចោលកិច្ចសន្យារួចមក យើងឃើញថា មូលហេតុនៃការលុបចោលកិច្ចសន្យាចែកជា ២ធំៗគឺ វិការៈនៃការបង្ហាញឆន្ទៈ និងកង្វះសមត្ថភាពរបស់ភាគី។ ច្បាប់ក៏បានកំណត់អំពីអ្នកមានសិទ្ធិលុបចោល វិធីនៃការលុបចោល/ការផ្តល់សច្ចានុមតិ និងអាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល។ ទោះបីកិច្ចសន្យាមានមូលហេតុនៃការលុបចោលក៏ដោយ ប្រសិនបើអ្នកមានសិទ្ធិលុបចោល មិនបានប្រកាសលុបចោលកិច្ចសន្យា នោះកិច្ចសន្យាមានសុពលភាព។ ម្យ៉ាងវិញទៀត ប្រសិនបើហួសអាជ្ញាយុកាលនៃការប្រកាសលុបចោលកិច្ចសន្យា បានន័យថា សិទ្ធិលុបចោលត្រូវបានរលត់ អ្នកមានសិទ្ធិលុបចោល មិនអាចអះអាងលុបចោលកិច្ចសន្យាបានទេ នោះកិច្ចសន្យាក្លាយជាកិច្ចសន្យាសុពល។ ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានប្រកាសលុបចោលកិច្ចសន្យា ក្នុងអំឡុងពេលដែលច្បាប់ផ្តល់សិទ្ធិលុបចោល នោះនឹងធ្វើឱ្យកិច្ចសន្យានោះបាត់បង់អានុភាព និងចាត់ទុកថាមោឃៈតាំងពីដំបូង។ ដោយសារតែផលប៉ះពាល់នៃកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល គឺចំពោះតែភាគី ដូចនេះច្បាប់ផ្តល់លទ្ធភាពដល់អ្នកមានសិទ្ធិលុបចោលជាអ្នកសម្រេចថាលុប ឬមិនលុប (ផ្តល់សច្ចានុមតិ)។ ការលុបចោល ឬសច្ចានុមតិ ត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀត ហើយមានអានុភាព នៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀត។ ដូចនេះ ការយល់ដឹងអំពីចំណុចសំខាន់ៗដែលពាក់ព័ន្ធនឹងការលុបចោលសន្យា ពិតជាសំខាន់ណាស់ ព្រោះក្នុងការបង្កើតកិច្ចសន្យា ភាគីតែងមានក្តីសង្ឃឹមចំពោះកិច្ចសន្យា និងចង់ឱ្យកិច្ចសន្យានោះមានសុពលភាព ដែលតម្រូវឱ្យភាគីជៀសវាងនូវមូលហេតុដែលនាំឱ្យមានការលុបចោល ឬមោឃភាព។ យ៉ាងណាមិញ ក្រោយពីបានសិក្សាលម្អិតអំពីការលុបចោលកិច្ចសន្យានៅក្នុងជំពូកទី១ រួចមក យើងនឹងធ្វើការសិក្សាលម្អិតអំពីមោឃភាពកិច្ចសន្យានៅក្នុងជំពូកទី២។

# ជំពូកទី២
# មោឃភាពកិច្ចសន្យា

យើងបានដឹងហើយថា មូលហេតុដែលនាំឱ្យកិច្ចសន្យាគ្មានសុពលភាពមាន ការប្រកាសលុបចោលកិច្ចសន្យាពីអ្នកដែលមានសិទ្ធិលុបចោល និងការលើកឡើងពីមោឃភាពកិច្ចសន្យា។ បន្ទាប់ពីបានធ្វើការសិក្សាទៅលើការលុបចោលកិច្ចសន្យានៅក្នុងជំពូកទី១ រួចមក ពេលនេះយើងនឹងធ្វើការសិក្សាជំពូកទី២ ដែលស្តីអំពី **មោឃភាពកិច្ចសន្យា**។ នៅក្នុងជំពូកទី២ នេះ យើងនឹងសិក្សាទៅលើចំណុចសំខាន់ៗដូចជា (២.១) និយមន័យនៃមោឃភាព (២.២) មូលហេតុនៃមោឃភាពកិច្ចសន្យា (២.៣) អ្នកមានសិទ្ធិលើកឡើងពីមោឃភាពកិច្ចសន្យា (២.៤) វិធីលើកឡើងពីមោឃភាពកិច្ចសន្យា (២.៥) អាជ្ញាយុកាលនៃការលើកឡើងពីមោឃភាពកិច្ចសន្យា និងចុងក្រោយ (២.៦) អានុភាពនៃមោឃភាពកិច្ចសន្យា។

## ២.១ និយមន័យ «មោឃភាព»

នៅក្នុងសទ្ទានុក្រមលេខ ១២៥ ក្នុងក្រមរដ្ឋប្បវេណី បានកំណត់និយមន័យនៃ **មោឃភាព** ជាពីរគឺ (ទី១) ជាភាពពុំមានអានុភាពតាមផ្លូវច្បាប់ នៃសកម្មភាពគតិយុត្ត ដែលផ្ទុយនឹងបញ្ញត្តិអំពីនីតិវិធីបណ្តឹង និង (ទី២) គឺជាទណ្ឌកម្មដែលប្រកាសដោយចៅក្រមលុបបំបាត់ចោលជាប្រតិសកម្មនូវលិខិតគតិយុត្ត មិនបានបំពេញលក្ខខណ្ឌដែលច្បាប់កំណត់ ឬសកម្មភាពណាមួយដែលផ្ទុយពីនីតិវិធីនៃច្បាប់។ **មោឃភាពកិច្ចសន្យា** គឺជាការបដិសេធអានុភាពនៃកិច្ចសន្យាដោយយោងលើកិច្ចសន្យាត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈមិនពិត ដូចមានចែងក្នុងមាត្រា៣៥៣ ឬ អត្ថន័យនៃកិច្ចសន្យាមានភាពខុសច្បាប់ ឬភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អដែលមានចែងក្នុងមាត្រា៣៥៤ ឬផ្ទុយនឹងទម្រង់ដែលច្បាប់តម្រូវឱ្យមាន។ តាមក្រមរដ្ឋប្បវេណី កិច្ចសន្យាដែលត្រូវបានចាត់ទុកថាមោឃៈ កិច្ចសន្យានោះត្រូវបានចាត់ទុកថាគ្មានសុពលភាពតាំងពីដំបូង។ ចំពោះការអះអាងពីមោឃភាពនៃកិច្ចសន្យា មាត្រា៣៥៧ បានកំណត់ឱ្យជនណាក៏ដោយ ក៏អាចអះអាងពីមោឃភាពបានដែរ ដោយមិនកំណត់ពីអាជ្ញាយុកាលឡើយ។

## ២.២ មូលហេតុនៃមោឃភាពកិច្ចសន្យា

បើទោះបីជាភាគីនៃកិច្ចសន្យាបានបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាមួយនឹងត្រូវបានចាត់ទុកជាមោឃៈ ដែលនាំឱ្យគេចាត់ទុកថាគ្មានអត្ថិភាពនៃកិច្ចសន្យាតាំងពីដំបូងប្រសិនបើមានមូលហេតុដូចជា ការបង្ហាញឆន្ទៈមិនពិត ឬ អត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ

ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ ឬ ទម្រង់នៃកិច្ចសន្យាមិនស្របតាមច្បាប់កំណត់។

### ២.២.១ ការបង្ហាញឆន្ទៈមិនពិត

**ការបង្ហាញឆន្ទៈមិនពិត** គឺជាការបង្ហាញឆន្ទៈក្នុងកិច្ចសន្យាដែលមានអត្ថន័យខុសពីឆន្ទៈពិតរបស់ភាគីម្ខាង ដោយមានការឃុបឃិតជាមួយភាគីម្ខាងទៀតនៃកិច្ចសន្យា ទាំងដឹងថាខុសពីឆន្ទៈខាងក្នុង [59] ហើយកិច្ចសន្យាដែលបង្កើតឡើងនោះ មានរូបភាពខាងក្រៅស្របច្បាប់។ កិច្ចសន្យាប្រភេទនេះនឹងត្រូវបានចាត់ទុកថា *មោឃៈ*។

យោងតាមមាត្រាខាងលើ កិច្ចសន្យាដែលធ្វើឡើងដោយការបង្ហាញឆន្ទៈមិនពិត ដើម្បីអាចអះអាងពីមោឃភាពបានត្រូវគោរពតាមលក្ខខណ្ឌចំនួនបួនគឺ៖

(១) ត្រូវមានអត្ថិភាពនៃការបង្ហាញឆន្ទៈ

(២) ឆន្ទៈដែលបានបង្ហាញខាងក្រៅមិនត្រូវគ្នានឹងឆន្ទៈខាងក្នុង

(៣) អ្នកបង្ហាញឆន្ទៈដឹងថាឆន្ទៈដែលបានបង្ហាញ មិនត្រូវគ្នានឹងឆន្ទៈខាងក្នុង និង

(៤) ការឃុបឃិតគ្នារវាងភាគី។

***ឧទាហរណ៍៖*** «ក» បានធ្វើកិច្ចសន្យាលក់កសិដ្ឋានដាំបន្លែធម្មជាតិ និងចិញ្ចឹមសត្វ ឱ្យទៅ «ខ» ដែលជាប្អូនប្រុសរបស់ខ្លួន។ តាមពិត កិច្ចសន្យាដែល «ក» និង «ខ» បានធ្វើ គឺជាការឃុបឃិតគ្នារវាងពួកគេទាំងពីរនាក់ប៉ុណ្ណោះ ដោយពួកគេមិនមានឆន្ទៈពិតប្រាកដក្នុងការទិញលក់កសិដ្ឋាននោះទេ។ «ក» សន្យាថានឹងឱ្យប្រាក់មួយចំនួនទៅ «ខ» បើ «ខ» ព្រមធ្វើជាយល់ព្រមទិញ កសិដ្ឋានរបស់ «ក» ក្នុងតម្លៃថោក ហើយប្រគល់មកឱ្យ «ក» វិញនៅពេលដែល «គ» ដែលជាម្ចាស់បំណុលរបស់ «ក» ឈប់មកទាមទារ រឹបអូសយកកសិដ្ឋាននោះ។ «ក» ធ្វើបែបនេះ ព្រោះ «ក» បានដឹងថា ឆ្នាំក្រោយរដ្ឋាភិបាលនឹងអនុវត្តគោលនយោបាយជួយជ្រោមជ្រែង លើកស្ទួយ និងស្វែងរកទីផ្សារសម្រាប់ផលិតផលកសិកម្មធម្មជាតិ ដូច្នេះហើយ «ក» រំពឹងថា កសិដ្ឋាននេះនឹងជួយរកចំណូលឱ្យគាត់បានច្រើន។

ដើម្បីអាចដឹងថា គេអាចលើកឡើងពីមោឃភាពកិច្ចសន្យាលក់ទិញកសិដ្ឋានដាំបន្លែធម្មជាតិ និងចិញ្ចឹមសត្វ ដែល «ក» បានធ្វើជាមួយ «ខ» ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតបានដែរឬយ៉ាងណានោះ គេត្រូវពិនិត្យទៅលើលក្ខខណ្ឌដូចខាងក្រោម៖

[59] មាត្រា៣៥៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- «ក» បានបង្ហាញឆន្ទៈលក់កសិដ្ឋានដាំបន្លែធម្មជាតិ និងចិញ្ចឹមសត្វ ទៅឱ្យ «ខ» (មានអត្ថិភាពនៃការបង្ហាញឆន្ទៈ ស្របតាមលក្ខខណ្ឌទី១)។
- តាមរយៈឧទាហរណ៍ខាងលើ «ក» គ្មានឆន្ទៈចង់លក់កសិដ្ឋានដាំបន្លែធម្មជាតិ និងចិញ្ចឹមសត្វ នោះឱ្យទៅ «ខ» ទេ។ ឆន្ទៈពិតប្រាកដរបស់ «ក» គឺ ទុកកសិដ្ឋានដាំបន្លែធម្មជាតិ និងចិញ្ចឹមសត្វ នោះជាកម្មសិទ្ធិរបស់ខ្លួនឯងដដែល (ឆន្ទៈដែលបានបង្ហាញចេញមកខាងក្រៅមិនត្រូវគ្នានឹងឆន្ទៈខាងក្នុង ស្របតាមលក្ខខណ្ឌទី២)។
- «ក» បានដឹងច្បាស់ពីការណ៍ដែលខ្លួនបានបង្ហាញឆន្ទៈមិនពិត ព្រោះ «ក» ដឹងថាខ្លួនមិនចង់លក់កសិដ្ឋានដាំបន្លែធម្មជាតិ និងចិញ្ចឹមសត្វឱ្យទៅ «ខ» ទេ តែខ្លួនធ្វើបែបនេះ គឺដើម្បីគេចពីការរឹបអូសកសិដ្ឋានពីសំណាក់ម្ចាស់បំណុលប៉ុណ្ណោះ (អ្នកបង្ហាញឆន្ទៈដឹងថាឆន្ទៈដែលបានបង្ហាញ មិនត្រូវគ្នានឹងឆន្ទៈខាងក្នុង ស្របតាមលក្ខខណ្ឌទី៣)។
- ក្នុងឧទាហរណ៍ខាងលើ «ខ» ក៏បានដឹងពីវត្តមាននៃការបង្ហាញឆន្ទៈមិនពិតរបស់ «ក» ដែរ ព្រោះ «ខ» បានព្រមទិញកសិដ្ឋានពី «ក» ក្នុងតម្លៃថោក និង ត្រូវប្រគល់មកឱ្យ «ក» វិញជាថ្នូរនឹងការទទួលបានប្រាក់មួយចំនួនពី «ក» (នេះសបញ្ជាក់ឱ្យឃើញថា ភាគីទាំងពីរមានការឃុបឃិតគ្នាក្នុងការបង្កើតកិច្ចសន្យាលក់ទិញកសិដ្ឋាននេះ ស្របទៅនឹងលក្ខខណ្ឌទី៤)។

តាមរយៈការបកស្រាយខាងលើបង្ហាញឱ្យឃើញថា លក្ខខណ្ឌទាំងបួននៃការបង្ហាញឆន្ទៈមិនពិត គឺ*ត្រូវបានបំពេញ*។ ដូច្នេះ គេអាចលើកឡើងពីមោឃភាពកិច្ចសន្យា ដោយផ្អែកទៅលើការបង្ហាញឆន្ទៈមិនពិតបាន ចំពោះកិច្ចសន្យាលក់ទិញកសិដ្ឋានខាងលើ។

ជាការគួរឱ្យចាប់អារម្មណ៍ផងដែរ ចំពោះករណី ***បបនីយផ្លូវចិត្ត*** ដែលមានចែងក្នុងមាត្រា ៣៥២ អាចធ្វើឱ្យមានការភាន់ច្រលំជាមួយនឹងការបង្ហាញឆន្ទៈមិនពិតបាន ដោយសារមានធាតុផ្សំស្រដៀងគ្នា។ ជាក់ស្តែង ***បបនីយផ្លូវចិត្ត*** គឺជាការបង្ហាញឆន្ទៈ ដោយអ្នកបង្ហាញឆន្ទៈដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតទេ។ ប៉ុន្តែ ទោះបីជាមានការបង្ហាញឆន្ទៈមិនពិត ក៏កិច្ចសន្យានោះនៅតែមានអានុភាពដែរ ដោយភាគីមិនអាចធ្វើការលើកឡើងពីការលុបចោល ឬ មោឃភាពដោយយោងលើបបនីយផ្លូវចិត្តបានឡើយ ដើម្បីជៀសវាងធ្វើឱ្យខូចប្រយោជន៍របស់ភាគីម្ខាងទៀតនៃកិច្ចសន្យា។

***ឧទាហរណ៍៖*** «ក» និយាយលេងជាមួយ «ខ» ថា ខ្លួននឹងព្រមលក់កាបូបម៉ាក Chanel ដែលខ្លួនទើបតែទិញក្នុងតម្លៃ ២ ២០០ ដុល្លារអាមេរិក ឱ្យទៅ «ខ» ក្នុងតម្លៃ ៥០០ ដុល្លាអាមេរិក បើ «ខ» មានប្រាក់ គ្រប់មកទិញភ្លាមៗ។ តាមពិត «ក» គ្មានឆន្ទៈនឹងលក់កាបូបនេះឱ្យទៅ «ខ» វិញនោះទេ

ព្រោះជាកាបូបដែលខ្លួនឯងស្រលាញ់ និងមានតម្លៃថ្លៃទៀតផង តែដោយសារតែឃើញ «ខ» ជាមនុស្សធម្មតា មិនប្រើរបស់ម៉ាកល្បី ហើយគិតថា «ខ» គ្មានលទ្ធភាពមានលុយ ៥០០ ដុល្លាមកទិញកាបូបនោះទេ ក៏ចង់លេងសើចជាមួយ «ខ»។ ករណីបែបនេះ ប្រសិនបើ «ខ» មិនបានដឹងពីឆន្ទៈដែលបង្ហាញចេញមក ជាឆន្ទៈមិនពិត ហើយ «ខ» ព្រមទិញកាបូបនោះមែន នោះ «ក» ត្រូវតែប្រគល់កាបូបនោះ ឱ្យទៅ «ខ» ។ យ៉ាងណាមិញ ប្រសិនបើ «ខ» ក៏បានដឹងពីអត្ថិភាពនៃការបង្ហាញឆន្ទៈមិនពិតនោះ កិច្ចសន្យានោះ ក៏នៅតែមានអានុភាពដែរ តែ «ក» អាចមិនអនុវត្តកាតព្វកិច្ចបាន។

**២.២.២ អត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ**

***បញ្ញត្តិអនុវត្តដោយបង្ខំ*** គឺជាបញ្ញត្តិដែលបដិសេធអានុភាព នៃសកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនោះ។ ជាទូទៅ បទប្បញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី គឺផ្តល់សិទ្ធិឱ្យភាគីនៃកិច្ចសន្យាអាចព្រមព្រៀង ឬកំណត់អត្ថន័យនៃកិច្ចសន្យាបានដោយសេរី តាមឆន្ទៈព្រមព្រៀងរបស់ភាគី ឬហៅថាជា *គោលការណ៍ស្វ័យភាពបុគ្គលឯកជន*។[60] នេះគឺជាគោលការណ៍មូលដ្ឋានមួយនៅក្នុងក្រមរដ្ឋប្បវេណី។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏អត្ថន័យនៃកិច្ចសន្យានោះមិនអាចផ្ទុយទៅនឹងបញ្ញត្តិអនុវត្តដោយបង្ខំបានឡើយ។ បញ្ហានៅត្រង់ថា មានបញ្ញត្តិមួយចំនួនចែងច្បាស់ថាជាបញ្ញត្តិអនុវត្តដោយបង្ខំ ដូចជា *បញ្ញត្តិស្តីពីការប្រាក់* ក្នុងមាត្រា៥៨៥ កថាខណ្ឌ៣ បានចែងថា ប្រសិនបើភាគីបានកំណត់អត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត កិច្ចសន្យានៃភាគដែលលើសពីកម្រិតនៃអត្រាការប្រាក់នោះ *ត្រូវទុកជាមោឃៈ* ហើយអ្នកខ្ចីមានករណីយកិច្ចសងចំពោះការប្រាក់ដែលត្រូវបានគណនាតាមអត្រាការប្រាក់ដែលត្រូវបានកម្រិតនោះតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតផងដែរ ទាក់ទងនឹងអាពាហ៍ពិពាហ៍ ក៏ត្រូវបានអនុញ្ញាតឱ្យប្តឹងមោឃភាពបានផងដែរ ប្រសិនបើ មានហេតុផលដែលមានចែងក្នុងមាត្រា៩៥៨ ដែលមានដូចជា ការគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគី ដោយសារការភាន់ច្រលំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងទៀត ឬភាគីមិនបានគោរពទៅតាមនីតិវិធីក្នុងការបង្កើតអាពាហ៍ពិពាហ៍ស្របតាមច្បាប់។ នេះជា*បញ្ញត្តិអនុវត្តដោយបង្ខំ*។ បន្ថែមពីនេះទៀត ជាបញ្ញត្តិអនុវត្តដោយបង្ខំដូចគ្នាផងដែរ ចំពោះបញ្ញត្តិនៃច្បាប់ការងារ ដែលកំណត់អំពីកម្រិតអតិបរមានៃម៉ោងធ្វើការប្រចាំសប្តាហ៍ ហើយប្រសិនបើនិយោជក និងកម្មករនិយោជិត ចុះកិច្ចសន្យាដែលបញ្ចូលកិច្ចព្រមព្រៀងម៉ោងធ្វើការដែលហួសពីកម្រិតអតិបរមានោះ កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈដោយសារតែបំពានបញ្ញត្តិអនុវត្តដោយបង្ខំទាក់ទងនឹងម៉ោងធ្វើការ។[61] ទោះបីជាយ៉ាងណា

[60] មាត្រា៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[61] មាត្រា១៣៧ នៃច្បាប់ការងារ ១៩៩៧

ក៏ដោយ ក៏មានបញ្ញត្តិមួយចំនួនមិនបានចែងច្បាស់ថាជាបញ្ញត្តិអនុវត្តដោយបង្ខំនោះទេ។ ដូច្នេះ ហើយទើបគេត្រូវមើលពីគោលគំនិតនៃមាត្រានោះថាជាបញ្ញត្តិអនុវត្តដោយបង្ខំ ឬមិនមែន។ ជាធម្មតា *បញ្ញត្តិអនុវត្តដោយបង្ខំ ជាបញ្ញត្តិដែលទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ រីឯបញ្ញត្តិដែលមិនទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ គេហៅថាជា**បញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត***។[62]

## ២.២.៣ អត្ថន័យកិច្ចសន្យាផ្ទុយនឹង សណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ

***សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ*** សំដៅដល់ប្រយោជន៍ទូទៅ និង ទំនៀមទម្លាប់លក្ខណៈសីលធម៌នៅក្នុងសង្គម។ ដូច្នេះ កិច្ចសន្យាមួយ ដែលមានអត្ថន័យបំពាននឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ កិច្ចសន្យានោះត្រូវទុកជាមោឃៈ។ គេមិនអាចបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងច្បាប់នោះទេ អំពីខ្លឹមសារនៃសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ព្រោះវាមានលក្ខណៈខុសគ្នាទៅតាមសម័យកាល និងតាមប្រទេសនីមួយៗ។ អត្ថន័យនៃសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ គួរត្រូវសម្រេចដោយយុត្តិសាស្ត្រ តាមករណីនីមួយៗ។[63] បន្ថែមពីនោះ បើទោះបីជាក្រមរដ្ឋប្បវេណីបានបញ្ញត្តិពីគោលការណ៍ស្វ័យភាពបុគ្គលឯកជនដែលជាគោលការណ៍មូលដ្ឋានមួយ ដោយផ្តល់ឱ្យភាគីនៃកិច្ចសន្យាមានសេរីភាពក្នុងការសម្រេចពីខ្លឹមសារកិច្ចសន្យារបស់ពួកគេដោយសេរីក៏ដោយ ក៏ខ្លឹមសារនៃកិច្ចសន្យានោះ ត្រូវមានអត្ថន័យសមរម្យផងដែរ។ នេះក៏ព្រោះថា បើគេអនុញ្ញាតឱ្យកិច្ចសន្យាដែលមានខ្លឹមសារប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ មានអានុភាពអនុវត្តដែរនោះ សង្គមនឹងពោរពេញដោយភាពអនាធិបតេយ្យ គ្មានសន្តិភាព សន្តិសុខ សុវត្ថិភាពជាក់ជាមិនខាន។

***ឧទាហរណ៍ទី១៖*** «ក» ជាជនក្រីក្រម្នាក់ បានធ្វើកិច្ចសន្យា លក់កែវភ្នែក ឱ្យទៅ «ខ» ក្នុងតម្លៃ ១០ ០០០ ដុល្លារ។ កិច្ចសន្យាបែបនេះត្រូវចាត់ទុកថាមោឃៈ ព្រោះវានឹងធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ ហើយច្បាប់មិនអនុញ្ញាតឱ្យធ្វើការជួញដូរលើផ្នែកណាមួយនៃសារពាង្គកាយរបស់មនុស្សឡើយ។

***ឧទាហរណ៍ទី២៖*** «ក» ជាអ្នកលើកអាហារនៅក្នុងភោជនីយដ្ឋានមួយកន្លែង។ នៅពេលកំពុងលើកអាហារឱ្យភ្ញៀវ ស្រាប់តែ «ក» បានជំពប់ជើងដួល ហើយធ្វើឱ្យអាហារនោះកំពប់លើភ្ញៀវដែលកំពុងអង្គុយ។ ភ្លាមនោះ ភ្ញៀវនោះមានការខឹងសម្បារយ៉ាងខ្លាំង ទោះជានាងសុំទោសយ៉ាងណាក៏មិនព្រម ថែមទាំងបានគម្រាមនាំនាងទៅប៉ុស្តិ៍ប៉ូលីសទៀត ហើយបាននិយាយថាបើនាងព្រមដោះ

[62] មេរៀនក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណីភាគ១, ក្រុមការងារក្រសួងយុត្តិធម៌, ទំព័រ ៤៧

[63] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, កំណត់មាត្រា៣៥៤

អាវរបស់នាងអស់ និងឈរនៅមុខហាងរយៈពេលមួយម៉ោងនោះ គេនឹងអត់ទោសឱ្យ។ ដោយសារភ័យពេក នាងក៏យល់ព្រម។ ស្រាប់តែអ្នកចាត់ការទូទៅនៅក្នុងភោជនីយដ្ឋានមកដល់ ក៏បានធ្វើការសុំទោស និងប្រាប់ឱ្យនាងមិនបាច់ដោះអាវដូចបានសន្យាទេ។ ជាធម្មតា ការអាក្រាតកាយនៅទីសាធារណៈបែបនេះ វាប៉ះពាល់ទៅដល់ទំនៀមទម្លាប់ សីលធម៌ដ៏ល្អផូរផង់របស់ខ្មែរ។ ដូច្នេះហើយ កិច្ចសន្យាណាដែលមានអត្ថន័យប៉ះពាល់ដល់ទំនៀមទម្លាប់ល្អ គឺមិនមានអានុភាពអនុវត្តឡើយ តួយ៉ាងដូចជាឧទាហរណ៍ខាងលើជាដើម គឺភ្ញៀវនោះ មិនអាចបង្ខំឱ្យអ្នកលើកអាហារនោះអនុវត្តតាមការសន្យានោះទេ ដោយសារសកម្មភាពនោះផ្ទុយនឹងទំនៀមទំលាប់ល្អ ហើយការព្រមព្រៀងនោះត្រូវបានចាត់ទុកថាជា*មោឃៈ*។

***ឧទាហរណ៍ទី៣៖*** «ក» និង «ខ» បង្កើតកិច្ចសន្យាដឹកជញ្ជូនគ្រឿងញៀនជាមួយគ្នា។ បន្ទាប់ពី «ក» បានបញ្ជូនគ្រឿងញៀនរួចរាល់ហើយ «ក» បានមកទារលុយថ្លៃដឹកជញ្ជូនដែល «ខ» បានសន្យាថាឱ្យ។ «ខ» មិនចាំបាច់អនុវត្តតាមអ្វីដែល ខ្លួនបានសន្យាទេ ព្រោះកិច្ចសន្យាដែល «ក» និង «ខ» បានធ្វើជាមួយគ្នានោះ គឺត្រូវបានមោឃៈ ហើយច្បាប់មិនទទួលស្គាល់ឡើយ ដោយសារកម្មវត្ថុនៃកិច្ចសន្យានេះ (ការដឹកជញ្ជូនគ្រឿងញៀន) ខុសទៅនឹងច្បាប់។[64]

### ២.២.៤ កិច្ចសន្យាផ្ទុយនឹងទម្រង់ដែលច្បាប់កំណត់

ជាគោលការណ៍ កិច្ចសន្យាកើតឡើង និងមានអានុភាពអនុវត្តបាន ឱ្យតែសំណើរ និងស្វីការត្រូវគ្នា ទោះបីជាយ៉ាងនេះក៏មានកិច្ចសន្យាមួយចំនួនតម្រូវឱ្យធ្វើឡើងតាមទម្រង់ដែលបានកំណត់ជាក់លាក់ ទើបអាចក្លាយជាកិច្ចសន្យាដែលមានអានុភាពអាចអនុវត្តបាន។ តួយ៉ាងដូចជា មាត្រា ៣៣៦ បានបញ្ញត្តិតម្រូវលក្ខខណ្ឌចាំបាច់ទាក់ទងនឹងកិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ ត្រូវធ្វើឡើងជាលិខិតយថាភូត ទើបកិច្ចសន្យានោះមានអានុភាព។ ដូច្នេះហើយប្រសិនបើ កិច្ចសន្យានោះមិនបានគោរពទៅតាមលក្ខខណ្ឌតម្រូវទេ កិច្ចសន្យានោះនឹងមិនមានសុពលភាពឡើយ។

***ឧទាហរណ៍៖*** នៅថ្ងៃទី០១ ខែមេសា ២០១៨ «ក» បានព្រមព្រៀងដោយផ្ទាល់មាត់ លក់ដីឱ្យទៅ «ខ» ក្នុងតម្លៃ ៣០ ០០០ដុល្លារ។ នៅថ្ងៃ ទី ០៣ ខែ មេសា ២០១៨ «ក» បានព្រមព្រៀង លក់ដីដដែលនោះ ឱ្យទៅ «គ» ក្នុងតម្លៃ ៥០ ០០០ដុល្លារ ដោយបានធ្វើជាលិខិតយថាភូត និងបានធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់។ «ខ» បានទាមទារឱ្យ «ក» ផ្ទេរកម្មសិទ្ធិលើដីមកឱ្យខ្លួន តែ «ក» បដិសេធ។ បើក្រលេកទៅមើលបញ្ញត្តិស្ដីពីកិច្ចសន្យាទិញលក់ មាត្រា៥២៨ កថាខណ្ឌ១ គឺបាន

[64] មាត្រា៤០, ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន, ២ មករា ២០១២

ចង្អុលបង្ហាញឱ្យអនុវត្តតាមមាត្រា១៣៥ ចំពោះករណីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ។ បានន័យថា ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុមានអានុភាពនៅពេលបានធ្វើការចុះបញ្ជីស្របតាមច្បាប់។ ដូច្នេះហើយ ករណីនេះ «ខ» មិនអាចទាមទារឱ្យ «ក» ប្រគល់ដី មកឱ្យខ្លួនបានទេ ដោយសារកិច្ចសន្យាដែល «ក» បានធ្វើជាមួយ «ខ» មិនមានសុពលភាពឡើយដោយត្រូវបានចាត់ទុកជាមោឃៈ ព្រោះមិនត្រូវនឹងទម្រង់ដែលច្បាប់កំណត់ ហើយក៏មិនអាចអះអាងជាមួយ «គ» បានដែរ។

ម្យ៉ាងវិញទៀត ចំពោះករណីកិច្ចសន្យាខ្ចីបរិភោគវិញ ការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់នឹងពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់អ្នកខ្ចីទេនោះ។[65] បន្ថែមពីនោះទៀតផងដែរ បើភាគីធ្វើការព្រមព្រៀងកំណត់អត្រាការប្រាក់ដែលហួសពីអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ នោះការព្រមព្រៀងនោះក៏មិនមានអានុភាពឡើយ បើមិនបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចី។[66]

ក្រៅពីនោះផងដែរ នៅក្នុងមាត្រា ១១៧០ កថាខណ្ឌ២ បានកំណត់យ៉ាងច្បាស់ថា ត្រូវចាត់ទុកជាមោឃៈ ចំពោះមតកសាសន៍ដែលមិនត្រូវនឹងទម្រង់ដែលបានបញ្ញត្តិនៅក្នុងក្រមនេះ។

***ឧទាហរណ៍៖*** លោក «ក» បានធ្វើមតកសាសន៍ដោយលិខិតយថាភូតដូចមានចែងក្នុងមាត្រា ១១៧៣។ ក៏ប៉ុន្តែ ពេលធ្វើនោះ បែរជាមានវត្តមានសាក្សីតែម្នាក់ប៉ុណ្ណោះ។ ដោយសារលក្ខខណ្ឌដែលកំណត់ក្នុងមាត្រាដដែលនេះ គឺតម្រូវឱ្យមានសាក្សី យ៉ាងតិចពីរនាក់ ដូចនេះ មតកសាសន៍នេះនឹងត្រូវចាត់ទុកថាមោឃៈ គ្មានអានុភាពឡើយ។

ស្រដៀងគ្នានេះដែរ ចំពោះមតកសាសន៍ដោយលិខិតឯកជន គឺតម្រូវឱ្យម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់ និងចុះថ្ងៃ ខែ ឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ។ បើម្ចាស់បណ្ដាំឱ្យគេសរសេរឱ្យ ឬ ត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជា អង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ។[67]

## ២.៣ អ្នកដែលមានសិទ្ធិប្ដឹងពីមោឃភាព

ខុសពីការលុបចោលកិច្ចសន្យា ដែលបានកំណត់ច្បាស់ពីអ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យាដែលអាចលុបចោលបាន ចំពោះមោឃភាពនៃកិច្ចសន្យាវិញ គឺ បានអនុញ្ញាតឱ្យ មិនត្រឹមតែ

[65] មាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[66] មាត្រា៥៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[67] មាត្រា១១៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ភាគីនៃកិច្ចសន្យាទេ តតិយជនផ្សេងទៀត ក៏អាចលើកឡើងពីមោឃភាពនៃកិច្ចសន្យាបានដែរ ឱ្យតែកិច្ចសន្យានោះមានលក្ខណៈត្រូវនឹងចំណុចណាមួយដែលនាំឱ្យកិច្ចសន្យានោះ ប្រឈមនឹងការលើកឡើងពីមោឃភាព។ ច្បាប់អនុញ្ញាតដូច្នេះ ព្រោះគោលបំណងនៃមោឃភាពគឺដើម្បីកុំឱ្យមានកិច្ចសន្យាមិនកើតចេញពីឆន្ទៈពិតប្រាកដរបស់ភាគី ឬអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ ឬទម្រង់នៃកិច្ចសន្យាផ្ទុយនឹងទម្រង់ដែលច្បាប់បានកំណត់។[68] ហើយអ្វីដែលសំខាន់នោះគឺ ផលប៉ះពាល់ពីកិច្ចសន្យាដែលត្រូវបានចាត់ទុកជាមោឃៈ មិនមែនមានតែលើភាគីនៃកិច្ចសន្យាប៉ុណ្ណោះទេ តែវាមានអានុភាពទៅលើសមាជិកសង្គមទាំងមូល ដូច្នេះហើយ ការដែលច្បាប់អនុញ្ញាតឱ្យជនទាំងអស់អាចអះអាងពីមោឃភាពបាន គឺមានភាពសមរម្យ និងសមហេតុសមផលណាស់។

## ២.៤ វិធីនៃការលើកឡើងពីមោឃភាព

ចំពោះកិច្ចសន្យាដែលមានមូលហេតុលើកឡើងពីមោឃភាព បានន័យថាកិច្ចសន្យានោះគ្មានអានុភាពតាំងពីដំបូងមកម្ល៉េះ។ ហេតុនេះហើយ ទោះបីជាមានអ្នកលើកឡើង ឬគ្មានអ្នកលើកឡើងពីមោឃភាពក៏ដោយ ក៏គ្មានអត្ថិភាពនៃកិច្ចសន្យាកើតឡើងដែរ។ ដូច្នេះ ការលើកឡើងពីមោឃភាពនៃកិច្ចសន្យា មិនចាំបាច់ធ្វើឡើងតាមផ្លូវតុលាការ ហើយក៏មិនមានភាពចាំបាច់ក្នុងការជូនដំណឹងទៅភាគីនៃកិច្ចសន្យាដែរ។

***ឧទាហរណ៍៖*** «ក» បានព្រមព្រៀងលក់ កូនស្រីរបស់ខ្លួនឱ្យទៅ «គ»។ ការព្រមព្រៀងក្នុងករណីនេះ គឺជាការជួញដូរមនុស្ស ដែលច្បាប់ហាមឃាត់មិនឱ្យប្រព្រឹត្តឡើយ។[69] ដូចនេះ វាមានមូលហេតុលើកឡើងពីមោឃភាព។ បើ «គ» ឱ្យ «ក» អនុវត្តតាមការព្រមព្រៀង ដោយត្រូវប្រគល់កូនស្រីរបស់ «ក» មកឱ្យខ្លួន នោះ «ក» មិនចាំបាច់ធ្វើតាមការព្រមព្រៀងទេ ដោយលើកហេតុផលថាការព្រមព្រៀងនោះមិនមានអានុភាពឡើយ។ ម្យ៉ាងទៀត កូនស្រីរបស់ «គ» ក៏អាចបដិសេធលើការព្រមព្រៀងរវាង «ក» និង «គ» បានដោយយោងលើមោឃភាពកិច្ចសន្យា ដែលនាំឱ្យគ្មានកាតព្វកិច្ចអនុវត្តតាមការព្រមព្រៀងនោះទេ។

[68] មាត្រា១១៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[69] មាត្រា១៣, ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ, ១៥ កុម្ភៈ ២០០៨។

## ២.៥. អាជ្ញាយុកាលនៃការលើកឡើងពីមោឃភាព

*អាជ្ញាយុកាល* គឺជាអំឡុងពេលមួយដែលកំណត់ដោយច្បាប់ ហើយប្រសិនបើអំឡុងពេលកំណត់នោះហួស វានឹងបង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬ ការរលត់សិទ្ធិណាមួយ។[70] ជាក់ស្តែងចំពោះកិច្ចសន្យាដែលមានវិការៈ ឬកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយជនដែលខ្វះសមត្ថភាព បើច្បាប់អនុញ្ញាតឱ្យភាគី លើកឡើងពីមូលហេតុដែលនាំឱ្យមានការលុបចោលកិច្ចសន្យានៅពេលណាក៏បាននោះ វានឹងធ្វើឱ្យភាគីម្ខាងទៀតនៃកិច្ចសន្យាទទួលរងផលប៉ះពាល់ជាមិនខាន។ ម្យ៉ាងវិញទៀត សកម្មភាពនៃការជួញដូរ ក៏នឹងមិនអាចធ្វើទៅបានដោយរលូនទៀតដែរ ជាពិសេសនៅពេលដែលកម្មវត្ថុនៃកិច្ចសន្យាដែលមានមូលហេតុលុបចោលនោះ ត្រូវបានធ្វើការផ្ទេរជាបន្តបន្ទាប់ពីបុគ្គលម្នាក់ ទៅបុគ្គលម្នាក់ទៀត ឬត្រូវបាត់បង់ដោយប្រការណាមួយ។ ដូច្នេះហើយទើបក្នុងករណីកិច្ចសន្យាដែលមានមូលហេតុលើកឡើងពីការលុបចោល ត្រូវបានកំណត់អាជ្ញាយុកាលច្បាស់លាស់។ ផ្ទុយទៅវិញ ការលើកឡើងពីមោឃភាពនៃកិច្ចសន្យា មិនត្រូវបានកំណត់ពីអាជ្ញាយុកាលទេ។ មានន័យថា ការលើកឡើងពីមោឃភាព អាចធ្វើឡើងដោយជនណាក៏បាន និងពេលណាក៏បាន។ នេះក៏ដោយសារតែ កិច្ចសន្យាដែលមានមូលហេតុលើកឡើងពីមោឃភាពនោះ មិនត្រឹមតែមានឥទ្ធិពលលើភាគីនៃកិច្ចសន្យាប៉ុណ្ណោះទេ តែវាមានឥទ្ធិពលទៅលើសង្គមទាំងមូល។

***ឧទាហរណ៍៖*** កិច្ចសន្យាជួញដូរមនុស្ស ប្រសិនបើ មានការកំណត់អាជ្ញាយុកាលក្នុងការលើកឡើងពីមោឃភាព បើមុនពេលចប់អាជ្ញាយុកាល គ្មានអ្នកលើកឡើងពីមោឃភាពទេ នោះភាគីនៃកិច្ចសន្យាត្រូវតែអនុវត្តតាមកាតព្វកិច្ច ដែលមានចែងក្នុងកិច្ចសន្យាប្រសិនបើមិនទាន់បានអនុវត្ត ហើយចំពោះអ្នកដែលត្រូវបានគេជួញដូរវិញ តើនឹងទៅជាយ៉ាងណា? វាក៏ដូចជាការលើកទឹកចិត្តដោយប្រយោលឱ្យអំពើជួញដូរមនុស្សកើតមានច្រើនឡើង ដែលនឹងបង្កឱ្យមានភាពវឹកវរក្នុងសង្គមទាំងមូល។ ដូច្នេះហើយការលើកឡើងពីមោឃភាពនៃកិច្ចសន្យា មិនត្រូវបានកំណត់អាជ្ញាយុកាលទេ។

## ២.៦ អានុភាពនៃមោឃភាពកិច្ចសន្យា

### ២.៦.១ មោឃភាពដាច់ខាត

ជាធម្មតា មិនមែនគ្រប់កិច្ចសន្យាដែលបានបង្កើតឡើងមកសុទ្ធតែមានអានុភាពអាចអនុវត្តបាននោះទេ។ កិច្ចសន្យាខ្លះអាចត្រូវបានលើកឡើងពីមោឃភាព ឯកិច្ចសន្យាខ្លះទៀតអាចត្រូវបានប្រកាសលុបចោលទៅវិញ។ នៅពេលកិច្ចសន្យាមួយ មានមូលហេតុប្រឈមនឹងនឹងការលើកឡើងពីមោឃភាព កិច្ចសន្យានោះគ្មានអានុភាពតាំងពីដំបូងមកម្លេះ គឺមិនដែលមានអានុភាពតាំងពីដើម

[70] សទ្ធានុក្រមលេខ ១៩៦។

មក ទោះបីជាមានអ្នកលើកឡើងពីមោឃភាព ឬគ្មានអ្នកណាលើកឡើងក៏ដោយ។[71] ដូច្នេះ ភាគីនៃកិច្ចសន្យាមិនអាចទាមទារឱ្យភាគីម្ខាងទៀតអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យាបានទេ។

***ឧទាហរណ៍១៖*** «ក» និង «ខ» ជាប្តីប្រពន្ធនឹងគ្នា។ «គ» ជាអ្នកមាន ហើយក៏ជាស្រីកំណាន់របស់ «ខ» ផងដែរ។ «គ» បានមកជួប «ក» ដើម្បីនិយាយចរចារថាបើ «ក» ព្រមលែងលះជាមួយ «ខ» នោះ «គ» ព្រមផ្តល់ប្រាក់ ១០០ ០០០ដុល្លារ ឱ្យ «ក»។ «ក» បានយល់ព្រម ហើយបានទទួលយកប្រាក់ទាំងនោះ។ ទទួលយកប្រាក់ហើយ «ក» មិនបានលែងលះជាមួយ «ខ» ទេ។ ក្នុងករណីនេះ «គ» មិនអាចប្តឹងទៅតុលាការដើម្បីទាមទារឱ្យ «ក» លែងលះជាមួយ «ខ» បាននោះទេ ព្រោះកិច្ចសន្យាឱ្យប្តីប្រពន្ធលែងលះគ្នាបែបនេះ មិនមានអានុភាពតាំងពីពេលបង្កើតមកម្លេះ ដោយសារ វាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។

យ៉ាងណាមិញ ប្រសិនបើភាគីបានអនុវត្តកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យាដែលត្រូវបានចាត់ទុកថាជាមោឃៈនោះ ភាគីដែលបានទទួលផលប្រយោជន៍ មានកាតព្វកិច្ចសងផលប្រយោជន៍ដែលខ្លួនបានទទួលត្រលប់មកភាគីម្ខាងទៀតវិញតាមសេចក្តីចម្រើនឥតហេតុ។[72]

***ឧទាហរណ៍២៖*** «ក» និង «ខ» បានបង្កើតកិច្ចសន្យាទិញលក់ ដី មួយកន្លែងក្នុងតម្លៃថោកជាងតម្លៃទីផ្សារ។ តាមពិត «ក» និង «ខ» គ្មានឆន្ទៈ លក់ទិញដីពិតប្រាកដទេ គឺកិច្ចសន្យារបស់ពួកគេធ្វើឡើងដោយការបង្ហាញឆន្ទៈមិនពិត ដើម្បីកុំឱ្យម្ចាស់បំណុលរបស់ «ក» អាចរឹបអូសយកដីនោះបាន។ «ក» និង «ខ» បានធ្វើកិច្ចសន្យាប្រគល់ប្រាក់ថ្លៃលក់ ហើយ «ខ» បានប្រគល់ប្រាក់ថ្លៃដីនោះ ឱ្យ «ក» ចំនួន ១ ០០០ ដុល្លារអាមេរិក ដើម្បីឱ្យគេជឿថា «ក» និង «ខ» ពិតជាបានលក់ទិញ ដីនោះមែន។ ករណីនេះ «ក» បានទទួលផលប្រយោជន៍។ ដោយសារកិច្ចសន្យានោះ មានមូលហេតុលើកឡើងពីមោឃភាព នោះ «ខ» អាចទាមទារប្រាក់ ១ ០០០ ដុល្លារអាមេរិកនោះ មកវិញបានតាមរយៈសេចក្តីចម្រើនឥតហេតុ។

ទោះបីជាយ៉ាងណាក៏ដោយ យោងតាមមាត្រា៧៤១ បានកំណត់ថា ការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតប្រយោជន៍ ចំពោះបុគ្គលដែលបានទទួលប្រយោជន៍ អាចធ្វើបាន ចំពោះតែការទាមទារនោះមិនធ្វើឱ្យផ្ទុយនឹងរបៀបរៀបរយសាធារណៈ និងទំនៀមទម្លាប់ល្អ ឬច្បាប់ដែលទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈប៉ុណ្ណោះ។

---

[71] មេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២, ក្រុមការងារក្រសួងយុត្តិធម៌, ទំព័រ ២, ឆ្នាំ ២០១៦

[72] មេរៀនក្រមរដ្ឋប្បវេណី, សៀវភៅភាគទី ២, ទំព័រ ៤៨, ឆ្នាំ ២០១៣

***ឧទាហរណ៍៣៖*** «ក» បានធ្វើកិច្ចសន្យាជួញដូរអាវុធខុសច្បាប់ជាមួយ «ខ» ។ «ក» បានប្រគល់អាវុធខុសច្បាប់ឱ្យទៅ «ខ» រួចហើយ តែ «ខ» មិនប្រគល់ប្រាក់តាមការព្រមព្រៀងទេ។ ករណីនេះបើទោះបីជាកិច្ចសន្យារវាង «ក» និង «ខ» ត្រូវចាត់ទុកថាមោឃៈក៏ដោយ ក៏ «ក» មិនអាចទាមទារឱ្យ «ខ» ប្រគល់អាវុធត្រលប់មកវិញ តាមសេចក្តីចម្រើនឥតហេតុបានទេ ព្រោះកម្មវត្ថុនៃកិច្ចសន្យាដែល «ក» និង «ខ» បានធ្វើជាមួយគ្នានោះ វាផ្ទុយទៅនឹងច្បាប់។

ម្យ៉ាងវិញទៀត យោងតាមការបកស្រាយនៅក្នុងកំណត់មាត្រានីមួយៗនៃក្រម កិច្ចសន្យាដែលទុកជាមោឃៈ ក៏អាចក្លាយទៅជាមានសុពលភាពវិញ ប្រសិនបើបញ្ញត្តិដែលស្តីពីការអនុវត្តដោយបង្ខំនោះត្រូវបាននិរាករណ៍ ឬការវាយតម្លៃពីភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អនោះមានការផ្លាស់ប្តូរ ហើយភាគីទាំងពីរបានផ្តល់សច្ចានុមតិលើកិច្ចសន្យាដែលទុកជាមោឃៈនោះ។[73]

***ឧទាហរណ៍៖*** «ក» និង «ខ» បានបង្កើតកិច្ចសន្យាអាពាហ៍ពិពាហ៍ជាមួយគ្នា ដោយក្នុងកិច្ចសន្យាមានអត្ថន័យថា កិច្ចសន្យាអាពាហ៍ពិពាហ៍នេះមានអានុភាពតែត្រឹមរយៈពេលបីឆ្នាំប៉ុណ្ណោះ។ បីឆ្នាំក្រោយ ពួកគេត្រូវតែលែងលះគ្នាជាដាច់ខាត។ ជាទូទៅ កិច្ចសន្យាប្រភេទនេះមិនមានអានុភាពទេ ព្រោះត្រូវមោឃភាពយោងតាមភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។ ក៏ប៉ុន្តែប្រសិនបើថ្ងៃខាងមុខ សង្គមយល់ថាកិច្ចសន្យាប្រភេទនេះមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អទេ ហើយ «ក» និង «ខ» យល់ព្រមផ្តល់សច្ចានុមតិ នោះកិច្ចសន្យានោះនឹងក្លាយទៅជាមានអានុភាព។

ជាការគួរឱ្យចាប់អារម្មណ៍ផងដែរ ទាក់ទងទៅនឹង កិច្ចសន្យាដែលកើតចេញពីការបង្ហាញឆន្ទៈមិនពិត បើទោះបីជាកិច្ចសន្យានោះប្រឈមនឹងការលើកឡើងពីមោឃភាព ដែលនាំឱ្យភាគីដែលបាត់បង់ផលប្រយោជន៍ អាចទាមទារផលប្រយោជន៍ត្រលប់មកវិញក៏ដោយ ក៏មិនអាចអះអាងចំពោះតតិយជនដែលមានផលប្រយោជន៍ទាក់ទង ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតមកធ្វើជាមូលដ្ឋានបានដែរ។[74] ទោះបីជាយ៉ាងណាក៏ដោយ បើតតិយជននោះ ជាជនទុច្ចរិត ឬមិនបានដឹងពីការបង្ហាញឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរនោះគេនៅតែអាចអះអាងចំពោះតតិយជនបាន។[75]

[73] មាត្រា៣៥៧, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

[74] មាត្រា៣៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[75] មាត្រា៣៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

***ឧទាហរណ៍៖*** «ក» និង «ខ» បានបង្កើតកិច្ចសន្យាលក់ទិញ ឡានមួយគ្រឿង ក្នុងគោលបំណងជៀសវាងកុំឱ្យម្ចាស់បំណុលអាចរឹបអូសឡាននោះទៅបាន ហើយកិច្ចសន្យានេះគ្រាន់តែជាការឃុបឃិតគ្នារវាង ភាគីទាំងពីរប៉ុណ្ណោះ ដោយភាគីទាំងពីរសន្យាថា មួយសប្តាហ៍ក្រោយនឹងត្រូវធ្វើបដិទានឱ្យគ្នាទៅវិញទៅមក។ ពីរថ្ងៃក្រោយមក «ខ» បានយករថយន្តនោះលក់ទៅឱ្យ «គ» ដែលជាតតិយជន។ «គ» ជឿជាក់ថារថយន្តនោះគឺជារបស់ «ខ» ពិតមែន ព្រោះ «ខ» មានឯកសារគ្រប់គ្រាន់ ដោយមិនបានដឹងពីទំនាក់ទំនងកិច្ចសន្យារវាង «ក» និង «ខ» ទេ។ ករណីនេះ «គ» ជាតតិយជន សុចរិត និងគ្មានកំហុស ដូច្នេះហើយ «ក» ឬ «ខ» មិនអាចធ្វើការទាមទារឱ្យ «គ» ប្រគល់រថយន្តមកវិញបានទេ។

### ២.៦.២ មោឃភាពដោយផ្នែក

យ៉ាងណាមិញ ក៏មានកិច្ចសន្យាមួយចំនួនទៀត នឹងត្រូវបានចាត់ទុកជាមោឃៈតែចំពោះផ្នែកណាដែលប៉ះពាល់ដល់បញ្ញត្តិអនុវត្តដោយបង្ខំ ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អប៉ុណ្ណោះ។ ចំពោះផ្នែកណាដែលមិនមានវិការៈទេ ផ្នែកនោះនឹងនៅតែមាន សុពលភាពដដែល។ នេះក៏ព្រោះថា មោឃភាពកិច្ចសន្យាដែលបានបង្កើតហើយនោះ វានឹងប៉ះពាល់ដល់បុគ្គលជាច្រើនដែលមានផលប្រយោជន៍ទាក់ទង ដោយសារតែបានធ្វើសកម្មភាពដោយគិតថា សកម្មភាពនោះមានសុពលភាព។

***ឧទាហរណ៍*** «ក» បានខ្ចី ប្រាក់ពី «ខ» ចំនួន ១ ០០០ ដុល្លារអាមេរិក ដោយមានការប្រាក់ ៥០% ក្នុងមួយឆ្នាំ។ តាមពិតអត្រាការប្រាក់ដែលច្បាប់បានកម្រិត គឺត្រឹមតែ១៨% ភាគរយក្នុងមួយឆ្នាំប៉ុណ្ណោះ។[76] តាមកិច្ចសន្យាខាងលើនេះ ចំពោះកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ គឺនៅតែមានសុពលភាពដដែល ប៉ុន្តែចំពោះផ្នែកការប្រាក់ដែលលើសពីការប្រាក់ដែលច្បាប់បានកម្រិតនោះ គឺត្រូវមោឃភាព។ ដូច្នេះ កូនបំណុលនៅតែមានកាតព្វកិច្ចសងប្រាក់ទៅតាមអត្រាការប្រាក់ដែលច្បាប់បានកម្រិត។

តាមរយៈការបកស្រាយខាងលើបង្ហាញឱ្យឃើញថា ក្រៅពីទុកលទ្ធភាពឱ្យអ្នកដែលមានសិទ្ធិលុបចោល លុបចោលកិច្ចសន្យាដែលអាចលុបចោលបានដោយសារកិច្ចសន្យានោះមានមូលហេតុវិការៈ ឬកិច្ចសន្យាបានបង្កើតឡើងដោយជនដែលខ្វះសមត្ថភាព ក្នុងន័យការពារផលប្រយោជន៍របស់គូភាគីនៃកិច្ចសន្យា នីតិបញ្ញត្តិក៏បានយល់ឃើញពីផលប៉ះពាល់ពីកិច្ចសន្យាមួយចំនួនទៀត ដែលអាចបង្កហានិភ័យចំពោះសណ្តាប់ធ្នាប់សាធារណៈ និងសង្គមទាំងមូលផងដែរ។

[76] ប្រការ១, ប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត, លេខ ១២៨ កយ.ប្រក/១១, ២២ ធ្នូ ២០១១

ហេតុនេះហើយ ច្បាប់ក៏បានអនុញ្ញាតឱ្យជនណាក៏អាចធ្វើការលើកឡើងពីមោឃភាពកិច្ចសន្យាទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈមិនពិត ឬកិច្ចសន្យាមានអត្ថន័យផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ឬសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ រួមទាំងកិច្ចសន្យាណាដែលមានទម្រង់មិនស្របតាមច្បាប់កំណត់ផងដែរ ព្រោះបើគេអនុញ្ញាតឱ្យកិច្ចសន្យាប្រភេទនេះមានអានុភាពអនុវត្តដែរនោះ វានឹងនាំមកនូវភាពវឹកវរ អនាធិបតេយ្យដល់សង្គមជាក់ជាមិនខាន។

# សេចក្តីសន្និដ្ឋាន

ផ្អែកលើការសិក្សាស្រាវជ្រាវ និងការបកស្រាយយ៉ាងលម្អិតទាក់ទងទៅនឹងប្រធានបទ «**ការលុបចោល និងមោឃភាពកិច្ចសន្យាក្រោមបទប្បញ្ញត្តិក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧**» បានបង្ហាញឱ្យឃើញថា ដើម្បីឱ្យកិច្ចសន្យាមួយមានអានុភាពអាចអនុវត្តបានស្របទៅតាមច្បាប់ គឺត្រូវគោរពលក្ខខណ្ឌអានុភាព និងលក្ខខណ្ឌសុពលភាពផងដែរ។ ប្រសិនបើលក្ខខណ្ឌត្រូវបានបំពាន ឬមិនត្រូវបានបំពេញទេនោះ នឹងនាំឱ្យមានទណ្ឌកម្មទៅលើកិច្ចសន្យាជាមិនខាន។ ទណ្ឌកម្មនោះគឺ កិច្ចសន្យានោះនឹងត្រូវបាត់បង់សុពលភាព ឬត្រូវបានចាត់ទុកថាគ្មានអត្ថិភាពនៃកិច្ចសន្យាតាំងពីដំបូង។ ជាក់ស្តែង ក្រមរដ្ឋប្បវេណីបានកំណត់ពីមូលហេតុដែលនាំអោយកិច្ចសន្យាគ្មានសុពលភាពប្រសិនបើកិច្ចសន្យានោះមានមូលហេតុដែលអាចលុបចោលបាន ហើយត្រូវបានប្រកាសលុបចោលដោយអ្នកដែលមានសិទ្ធិលុបចោល និងកិច្ចសន្យានោះមានមូលហេតុដែលត្រូវបានចាត់ទុកជាមោឃៈ។

ទោះបីជាការលុបចោលកិច្ចសន្យា និងមោឃភាពកិច្ចសន្យាសុទ្ធតែជាមូលហេតុដែលនាំឱ្យកិច្ចសន្យាគ្មានសុពលភាពក៏ដោយ ក៏ករណីទាំងពីរនេះមានចំណុចខុសគ្នាជាច្រើន។ ក្នុងនោះមានដូចជា មូលហេតុដែលអាចប្រកាសលុបចោលកិច្ចសន្យាបានគឺ ផ្អែកទៅលើវត្តមានវិការៈក្នុងការបង្ហាញឆន្ទៈ និងកិច្ចសន្យាត្រូវបានបង្កើតឡើងដោយជនដែលខ្វះសមត្ថភាព ចំណែកឯមូលហេតុដែលអាចអះអាងពីមោឃភាពបាន គឺផ្អែកទៅលើកិច្ចសន្យាទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈមិនពិត ឬកិច្ចសន្យាមានអត្ថន័យផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ឬសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ រួមទាំងកិច្ចសន្យាណាដែលមានទម្រង់មិនស្របតាមច្បាប់កំណត់។ បន្ថែមពីនោះទៀតផងដែរ ការលុបចោលកិច្ចសន្យាអាចធ្វើបានដោយជនដែលមានកំណត់ច្បាស់ក្នុងក្រមរដ្ឋប្បវេណីប៉ុណ្ណោះ ហើយក៏មានកំណត់អាជ្ញាយុកាលសម្រាប់ឱ្យធ្វើការប្រកាសលុបចោលកិច្ចសន្យាដែលមានមូលហេតុលុបចោលផងដែរ។ ផ្ទុយទៅវិញ ការអះអាងពីមោឃភាពនៃកិច្ចសន្យា មិនត្រឹមតែភាគីនៃកិច្ចសន្យា ឬអ្នកតំណាងនោះទេ នរណាៗក៏អាចអះអាងពីមោឃភាពបានដែរ ដោយមិនកំណត់ពីអាជ្ញាយុកាលនោះទេ ដោយសារកិច្ចសន្យាដែលមានមូលហេតុលើកឡើងពីមោឃភាពគឺប៉ះពាល់ដល់សង្គមទាំងមូល ហើយការមិនកំណត់អាជ្ញាយុកាលនេះគឺមានភាពចាំបាច់ណាស់ ព្រោះបើច្បាប់កំណត់អាជ្ញាយុកាល ហើយបើអំឡុងពេលនោះត្រូវបានបញ្ចប់ កិច្ចសន្យានោះនឹងមានសុពលភាព ឯភាគីដែលមានកាតព្វកិច្ចត្រូវតែអនុវត្ត ឬប្រសិនបើអនុវត្តរួចហើយ ក៏មិនអាចទាមទារអ្វីមកវិញបានដែរ។ លើសពីនេះទៀត ចំពោះកិច្ចសន្យាដែលមានមូលហេតុអាចលុបចោលបាន ក៏អាចត្រូវបានផ្តល់សច្ចានុមតិបានដែរ ហើយបើសច្ចានុមតិត្រូវបានផ្តល់ នាំឱ្យកិច្ចសន្យា

នោះមានសុពលភាពពេញលេញ ខុសពីកិច្ចសន្យាដែលមានមូលហេតុមោឃភាព គឺច្បាប់មិនបាន អនុញ្ញាតឱ្យផ្តល់សច្ចានុមតិដើម្បីអោយមានសុពលភាពបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ បើទៅថ្ងៃខាងមុខ សង្គមមានការប្រែប្រួល ហើយបញ្ញត្តិអនុវត្តដោយបង្ខំមានការប្រែប្រួល ឬការឱ្យនិយមន័យលើសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អមានការកែប្រែ នោះអាចនឹងមានការអនុញ្ញាត្តិឱ្យផ្តល់សច្ចានុមតិក៏អាចថាបាន។ ចំណុចខុសគ្នាមួយទៀតនោះគឺ វិធីក្នុងការលុបចោលកិច្ចសន្យាគឺត្រូវធ្វើការជូនដំណឹងទៅភាគីម្ខាងទៀតនៃកិច្ចសន្យា ដើម្បីឱ្យភាគីម្ខាងទៀតដឹងពីការលុបចោល បើមិនដូច្នេះទេវាអាចនឹងបង្កឱ្យមានភាពស្មុគស្មាញកាន់តែខ្លាំង ជាពិសេសនៅពេលដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានផ្ទេរពីបុគ្គលម្នាក់ទៅអ្នកផ្សេងទៀតជាបន្តបន្ទាប់ ឬត្រូវបានបាត់បង់ដោយប្រការណាមួយ ខណៈពេលដែលកិច្ចសន្យាដែលមានមូលហេតុមោឃភាព មិនមានភាពចាំបាច់ក្នុងការជូនដំណឹងទៅភាគីនៃកិច្ចសន្យាទេ ព្រោះកិច្ចសន្យាដែលមានមូលហេតុមោឃភាព គ្មានអត្ថិភាពនៃកិច្ចសន្យាតាំងពីដំបូងមកម្ល៉េះ។ ចំពោះអានុភាពនៃការលុបចោលកិច្ចសន្យាដែលអាចលុបចោលបានគឺ កិច្ចសន្យានោះមានអានុភាពអនុវត្តរហូតដល់ពេលដែលមានការប្រកាសពីការលុបចោលកិច្ចសន្យា បានន័យថានៅពេលអ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យា លុបចោលកិច្ចសន្យា នោះកិច្ចសន្យានោះនឹងត្រូវបានចាត់ទុកជាមោឃៈ ឬគ្មានសុពលភាពតាំងពីដំបូង។

ដូចបានរៀបរាប់ពីខាងលើ ក្រោយពីឆ្លងផុតសង្គ្រាមដែលកើតមានផ្ទួនៗ ប្រទេសកម្ពុជាក៏ចាប់ផ្តើមមានការអភិវឌ្ឍជាបន្តបន្ទាប់ ជាពិសេសទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ សំណង់អាគារ រួមជាមួយនឹងការដើរលើសេដ្ឋកិច្ចទីផ្សារសេរី ដែលធ្វើឱ្យទំនាក់ទំនងកិច្ចសន្យាកើតមានឡើងកាន់តែច្រើន ស្របពេលដែលចំណេះដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ ក៏ដូចជាមន្ត្រីអនុវត្តច្បាប់ស្ថិតនៅក្នុងកម្រិតទាបនៅឡើយ ដែលនាំឱ្យការអនុវត្តទៅតាមក្រឹត្យក្រមនៃច្បាប់នៅតែជាបញ្ហាប្រឈម។ ពួកយើងសង្ឃឹមថា សារណានេះនឹងក្លាយជាធនធានឯកសារមួយ សំរាប់ជាជំនួយដល់ការពង្រឹងចំណេះដឹងផ្នែកច្បាប់ដល់សាធារណជន ក៏ដូចជា ជាឯកសារជំនួយដល់អ្នកសិក្សាស្រាវជ្រាវលើប្រធានបទនេះផងដែរ។

# អនុសាសន៍

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងខាងលើ នាងខ្ញុំទាំងពីរនាក់សូមសំណូមពរដល់អ្នកដែលពាក់ព័ន្ធដូចជា៖

***១. រដ្ឋាភិបាល៖*** ជាពិសេសក្រសួងពាក់ព័ន្ធនានាបន្តពង្រឹង លើកកម្ពស់ ផ្សព្វផ្សាយ ចំណេះដឹងផ្នែកច្បាប់អោយបានទូលំទូលាយបន្ថែមទៀត តាមរយៈការដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ក្រោមឧត្តមសិក្សានូវចំណេះដឹងជាមូលដ្ឋានផ្នែកច្បាប់ ក៏ដូចជាការបង្កើតជាកម្មវិធីផ្សព្វផ្សាយផ្សេងៗ ទាំងតាមរយៈការចុះទៅដល់សហគមន៍ផ្ទាល់ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដោយសារប្រជាពលរដ្ឋភាគច្រើន ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាលពិតជាមិនសូវបានចាប់អារម្មណ៍ ឬទទួលបានចំណេះដឹងច្បាប់ទេ ខណៈច្បាប់ថ្មីៗបានបង្កើតឡើងជាបន្តបន្ទាប់។

***២. ស្ថាប័នតុលាការ៖*** ពន្លឿនការដោះស្រាយវិវាទដែលពលរដ្ឋបានដាក់បណ្តឹងទៅឱ្យបានលឿន និងមានប្រសិទ្ធិភាពជាងនេះទៀត ព្រោះកាលណានីតិវិធីបណ្តឹងមានរយៈពេលយូរ ប្រជាពលរដ្ឋគាត់មិនចង់ទៅតុលាការទេ ដោយសារគាត់ត្រូវចំណាយច្រើនទោះបីជារឿងខ្លះគាត់ជាអ្នកបាត់បង់ប្រយោជន៍ក៏ដោយ។

***៣. មន្ត្រីរាជការ សិស្ស និស្សិត៖*** បុគ្គលទាំងនេះ ត្រូវបានចាត់ទុកជាអ្នកដែលចំណេះដឹង និងមានការយល់ដឹងអំពីច្បាប់ ក៏ដូចជាព័ត៌មានផ្សេងៗ ច្បាស់ជាងប្រជាពលរដ្ឋ។ ដូចនេះ សិស្ស និស្សិត មន្ត្រីរាជការ គួរធ្វើខ្លួនជាគំរូ ដោយគោរពច្បាប់ និងមិនប្រព្រឹត្តអ្វីដែលល្មើសច្បាប់ ហើយជាពិសេស ត្រូវមានស្មារីចេះចែករំលែក ក្នុងនាមជាខ្មែរដូចគ្នា។

***៤. ប្រជាពលរដ្ឋ៖*** ប្រជាពលរដ្ឋគួរចូលរួមក្នុងការអនុវត្តច្បាប់ឱ្យបានខ្ជាប់ខ្ជួន ស្របតាមភាពសុចរិត និងស្មោះត្រង់ ព្រោះទាល់តែគាត់គោរពតាមច្បាប់ ទើបគេអាចប្រើប្រាស់ច្បាប់ការពារគាត់បាន។ ពួកគាត់ក៏គួរស្វះស្វែង ស្វែងយល់ពីច្បាប់នានា តាមដែលអាចធ្វើបាន ព្រោះយើងទាំងអស់គ្នារស់នៅក្នុងសង្គមនីតិរដ្ឋ ការយល់ដឹងពីច្បាប់គឺជារឿងសំខាន់។

# ឯកសារយោង


១. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

២. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ២ មករា ២០១២

៣. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ, ១៥ កុម្ភៈ ២០០៨

៤. ច្បាប់ស្តីពីការងារ, ១៣ មីនា ១៩៩៧

៥. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១, ០៩ ធ្នូ ២០០៩

៦. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, ១០ មេសា ២០១០

៧. សៀវភៅក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ របស់ក្រសួងយុត្តិធម៌, ធ្នូ ២០១៥

៨. ប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត, លេខ ១២៨ កយ.ប្រក/១១, ២២ ធ្នូ ២០១១

៩. សន្ធានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

# បញ្ជីរាយនាមឧបសម្ព័ន្ធ

១. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ (មាត្រាពាក់ព័ន្ធ)

២. គំរូកិច្ចសន្យាគ្រប់ប្រភេទ

៣. ឯកសារគំរូលើកិច្ចសន្យាខ្ចីបរិភោគ

៤. ពាក្យស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី

៥. ច្បាប់ស្តីពីការងារ (ទំព័រ៥៦)

៦. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ទំព័រ២២-២៥)

៧. ច្បាប់ស្តីពីការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ទំព័រ៩)

៨. ប្រកាសស្តីពីការកំណត់ការប្រាក់